E

**អត្ថបទមិនទាន់បានកែសំរួល**

ការចែកចាយទូទៅ
E/CN.4/2006/110/Add.1
xx ខែមីនា ឆ្នាំ២០០៦
អត្ថបទដើមៈ អង់គ្លេស

គណៈកម្មការសិទ្ធិមនុស្ស
សម័យប្រជុំលើកទី៦២
ចំណុចទី១៩ នៃរបៀបវារៈបណ្តោះអាសន្ន

# សេវាប្រឹក្សាយោបល់ និងសហប្រតិបត្តិការបច្ចេកទេស ក្នុងវិស័យសិទ្ធិមនុស្ស

របាយការណ៍របស់លោក **យ៉ាស្ស ហ្គាយ** តំណាងពិសេស
នៃលោកអគ្គលេខាធិការអ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

# សេចក្តីបន្ថែម

របាយការណ៍របស់លោកតំណាងពិសេសនៃលោកអគ្គលេខាធិការអ.ស.បទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ត្រូវបានធ្វើរួចរាល់កាលពីថ្ងៃទី១០ ខែមករា ឆ្នាំ២០០៦។ បន្ទាប់ពីនោះមក គេឃើញមានការវិវត្តន៍គួរឱ្យកោតសរសើរជាពិសេសទាក់ទងទៅនឹងការបង្កើតឱ្យមានបរិយាកាសដែលនាំឱ្យមានសកម្មភាពនយោបាយស្របច្បាប់។ ការវិវត្តន៍ទាំងនោះរួមមានការដោះលែងឥស្សរជននានាដែលសកម្មក្នុងជីវភាពសាធារណៈពីការឃុំឃាំងបណ្តោះអាសន្នដែលរឿងក្តីរបស់ពួកគេត្រូវបានសរសេរនៅក្នុងរបាយការណ៍នេះ ការលើកលែងទោស និងការផ្តល់អភ័យឯកសិទ្ធិដល់សមាជិកសភានៃគណៈសមរង្ស៊ីឡើងវិញ និងសេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រីគាំទ្រពីការដាក់បទបរិហារកេរ្តិ៍ ថាមិនមែនជាបទល្មើសព្រហ្មទណ្ឌ ។ លោកតំណាងពិសេស បានដឹងយ៉ាងច្បាស់អំពីព្រឹត្តិការណ៍ជាវិជ្ជមានទាំងនេះ ហើយបន្តតាមដានការវិវត្តន៍នេះយ៉ាងយកចិត្តទុកដាក់។ លោកនឹងមកបំពេញបេសកម្មនៅប្រទេសកម្ពុជាជាលើកទីពីរនៅខែមីនានេះ ដើម្បីស្វែងយល់អំពីសភាពការណ៍ថ្មីៗថែមទៀត ហើយពិភាក្សាពីរបាយការណ៍ និងអនុសាសន៍របស់លោកជាមួយរាជរដ្ឋាភិបាល មុនពេលលោកដាក់របាយការណ៍នេះជូនគណៈកម្មការសិទ្ធិមនុស្សអ.ស.ប នៅក្នុងសម័យប្រជុំលើកទី៦២របស់ខ្លួន។

អង្គការសហប្រជាជាតិ E

សំរាប់ចែកចាយជាទូទៅ

ក្រុមប្រឹក្សាសេដ្ឋកិច្ច
និង សង្គមកិច្ច

E/CN.4/2006/110
ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០០៦
អត្ថបទដើម: ភាសាអង់គ្លេស

គណៈកម្មាធិការសិទ្ធិមនុស្ស
សម័យប្រជុំលើកទី ៦២
របៀបវារៈបណ្ដោះអាសន្ន ចំណុចទី ១៩

# សេវាប្រឹក្សាយោបល់ និង សហប្រតិបត្តិការផ្នែកបច្ចេកទេស ក្នុងវិស័យសិទ្ធិមនុស្ស

## របាយការណ៍របស់លោក យ៉ាស្ស ហ្គាយ តំណាងពិសេសរបស់លោកអគ្គលេខាធិការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅប្រទេសកម្ពុជា

## សេចក្តីសង្ខេប

របាយការណ៍នេះ ត្រូវបានដាក់ជូន អនុលោមតាមសេចក្តីសំរេចលេខ២០០៥/៧៧ របស់គណៈកម្មការសិទ្ធិមនុស្ស ។ នៅថ្ងៃទី១ ខែវិច្ឆិកា លោក**យ៉ាស្ស ហ្គាយ**បានទទួលការតែងតាំងជាតំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ។

នៅក្នុងពេលបំពេញបេសកកម្មលើកដំបូងរបស់លោកមកកាន់ប្រទេសកម្ពុជា ចាប់ពីថ្ងៃទី២៨ ខែវិច្ឆិកា ដល់ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៥ លោក**យ៉ាស្ស ហ្គាយ** បានផ្តោតការយកចិត្តទុកដាក់ជាពិសេសលើរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា វិស័យយុត្តិធមិ និងនីតិរដ្ឋ ព្រមទាំងលើសេរីភាពក្នុងការបង្កើតសមាគម ការជួបប្រជុំ និងការសំដែងមតិ ។ លោកបានសំគាល់ឃើញមានបរិយាកាសតានតឹង ចំពោះការចូលរួម និងការអនុវត្តន៍សិទ្ធិប្រជាធិបតេយ្យ ។ រដ្ឋាភិបាលបានធ្វើការប្តឹងផ្តល់ជារឿយៗ តាមរយៈតុលាការប្រឆាំងនឹងមតិទិទៀន និងមតិជំទាស់ ដែលបង្កការលំបាកកាន់តែច្រើនដល់អ្នកនយោបាយមកពីគណៈបក្សប្រឆាំង សហជីពកម្មករ អ្នកសារព័ត៌មាន សង្គមស៊ីវិល និងអង្គការសិទ្ធិមនុស្សនានា ក្នុងការសំដែងមតិ ឬក្នុងការបំពេញតួនាទីរបស់ខ្លួនដោយសេរី ។ នៅខណៈពេលកំពុងសរសេរបញ្ចប់របាយការណ៍នេះ មានឥស្សរៈជន និង សកម្មជនល្បីឈ្មោះមួយចំនួន ដែលជាប់ចោទពីបទបរិហារកេរ្តិ៍ បទផ្សាយព័ត៌មានមិនពិត និងបទញុះញង់ មិនអាចវិលត្រឡប់ចូលប្រទេសកម្ពុជាវិញ ឬកំពុងជាប់ពន្ធនាគារបណ្តោះអាសន្នរងចាំសវនាការ ។

ប្រទេសកម្ពុជាមានរដ្ឋធម្មនុញ្ញដ៏ល្អមួយ ដែលដាក់បញ្ចូលលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ ដែលក្នុងនោះ កម្ពុជាគឺជារដ្ឋភាគីមួយ ប៉ុន្តែរដ្ឋធម្មនុញ្ញនេះមិនត្រូវបានគោរពតាមទាំងស្រុងនោះទេ ហើយការធានាការពាររដ្ឋធម្មនុញ្ញ ក៏នៅមិនទាន់បានរឹងមាំដែរ ។ ប្រទេសកម្ពុជាបន្តអនុវត្តបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌអន្តរកាល ដែលបានរៀបចំព្រាងដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា ហើយដែលបានអនុម័តដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ក្នុងគោលដៅប្រើប្រាស់ជាវិធានការបណ្តោះអាសន្នតែប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ទាំងឡាយដែលបង្កើតឱ្យមានជាក្របខ័ណ្ឌមូលដ្ឋានគតិយុត្តិចាំបាច់សំរាប់ការកសាងនីតិរដ្ឋនៅកម្ពុជា នៅមិនទាន់បានអនុម័តនៅឡើយទេ ។ លោកតំណាងពិសេសជឿថាមានលំនាំមួយក្នុងការអនុវត្តច្បាប់កម្ពុជាបច្ចុប្បន្ននេះផងដែរ ដែលថាការរំលោភច្បាប់ គឺដើម្បីគោលបំណងខាងនយោបាយ ។ របាយការណ៍នេះបានកត់សំគាល់ផងដែរថា បញ្ហានិទណ្ឌភាពមានការរីករាលដាល ចំពោះជនទាំងឡាយដែលមានមុខតំណែងខ្ពស់ខាងនយោបាយ ឬមានទ្រព្យសម្បត្តិច្រើន ។

របៀបរបបគ្រប់គ្រង និងប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិរបស់កម្ពុជា នៅតែជាបញ្ហាចម្បងជាដដែល ។ រដ្ឋាភិបាលមិនទាន់បានផ្សព្វផ្សាយព័ត៌មានស្ដីពីដីរដ្ឋ និងធនធានធម្មជាតិ ដែលខ្លួនបានផ្ដល់សម្បទានឱ្យទៅក្រុមហ៊ុនឯកជនផ្សេងៗ និងយោធា ក្រោមឈ្មោះអភិវឌ្ឍន៍នោះទេ ។ ការប្រើប្រាស់និងការរំលោភយកធនធានទាំងនេះ បង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ ដែលរាប់បញ្ចូលទាំងប្រជាពលរដ្ឋជនជាតិដើមភាគតិច ដែលជាអ្នកងាយរងគ្រោះជាងគេបំផុត ។ បញ្ហានេះមានភាពទូលំទូលាយខ្លាំងណាស់ ហើយត្រូវការឱ្យមានការយកចិត្តទុកដាក់បំផុត ពីគ្រប់ស្រទាប់ជាន់ថ្នាក់ និងអ្នកទាំងឡាយដែលពាក់ព័ន្ធ ។

# មាតិកា

វក្យខ័ណ្ឌ

សេចក្តីផ្តើម.......... ១-៣

I. វិធីសាស្ត្រ និង កិច្ចដំណើរការ.......... ៤-៩

II. រដ្ឋធម្មនុញ្ញ .......... ១០-១១

III. ការការពាររដ្ឋធម្មនុញ្ញ..........

ក. របបរាជានិយម.......... ១២-១៣

ខ. ក្រុមប្រឹក្សាធម្មនុញ្ញ.......... ១៤

គ. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម .......... ១៥-១៧

ឃ. សមាជជាតិ.......... ១៨

IV. វិស័យយុត្តិធម៌ និងនីតិរដ្ឋ.......... ១៩

ក. និទណ្ឌភាព.......... ២០-២៦

ខ. ការអនុវត្តន៍ច្បាប់ចាំបាច់មួយចំនួន.......... ៧-២៨

គ. ឯករាជ្យភាពនៃតុលាការ.......... ២៩

V. ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ.......... ៣០-៤១

VI. ការបង្កើតបរិយាកាស ដែលនាំឱ្យមានសកម្មភាពនយោបាយស្របច្បាប់.......... ៤២

ក. ការព្យួរអភ័យឯកសិទ្ធិសមាជិករដ្ឋសភា .......... ៤៣-៤៥

ខ. ការបរិហារកេរ្តិ៍.......... ៤៦-៥៤

គ. រឿងក្តីថ្មីៗ.......... ៥៥-៦០

ឃ- សង្គមស៊ីវិល និងសេរីភាពក្នុងការបង្កើតសមាគម និងការប្រជុំ.......... ៦១-៦៤

VII. សេចក្តីសន្និដ្ឋាន និង អនុសាសន.......... ៦៥-៧៥

# សេចក្ដីផ្ដើម

១. របាយការណ៍នេះត្រូវបានដាក់ជូន អនុលោមតាមសេចក្ដីសំរេចលេខ២០០៥/៧៧ ដែលគណៈកម្មការសិទ្ធិមនុស្សបានអនុម័តនៅសម័យប្រជុំលើកទី៦១ របស់ខ្លួនកាលពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៥ ។ នៅថ្ងៃទី១ខែវិច្ឆិកា លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានប្រកាសតែងតាំងលោក **យ៉ាស្ស ហ្គាយ** ជាតំណាងពិសេសថ្មីទទួលបន្ទុកសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ក្រោយពីមានការលាលែងពីតំណែងរបស់លោកភិថឺរ លយប្រែកត៍ កាលពីថ្ងៃទី៣១ ខែធ្នូ ។ នេះគឺជារបាយការណ៍លើកទី១របស់លោក **យ៉ាស្ស ហ្គាយ** ដែលត្រូវដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស ។

២. លោក **យ៉ាស្ស ហ្គាយ** បានធ្វើទស្សនៈកិច្ចលើកទី១ មកកាន់ប្រទេសកម្ពុជាក្នុងនាមជាតំណាងពិសេស ពីថ្ងៃទី២៨ ខែវិច្ឆិកា ដល់ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៥ ។ ក្នុងកំឡុងពេលបេសកកម្មរបស់លោក លោកបានចូលក្រាបបង្គំគាល់ព្រះមហាក្សត្រ ព្រះបាទបរមនាថ នរោត្ដម សីហមុនី និងបានជួបតំណាងជាន់ខ្ពស់ជាច្រើនរបស់រាជរដ្ឋាភិបាលកម្ពុជា រួមមាន ប្រធានព្រឹទ្ធសភា រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ក្រសួងការបរទេសនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃ ក្រសួងអប់រំ និងក្រសួងយុត្តិធម៌ ។ លោកបានជួបជាមួយប្រធានគណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋាភិបាលកម្ពុជា តុលាការ តំណាងគណៈបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលនិងសហគមន៍ សហជីព អ្នកសម្របសម្រួលអចិន្ត្រៃន៍នៃអ.ស.បប្រចាំកម្ពុជា ក្រុមអ.ស.បប្រចាំប្រទេសកម្ពុជា និងភ្នាក់ងារសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍ទ្វេភាគី និងពហុភាគីនានា ព្រមទាំងសហគមន៍អ្នកការទូតផងដែរ ។ លោកបានជួបសួរសុខទុក្ខអ្នកតំណាងរាស្ត្រ ជាម ច័ន្ទនី នៅពន្ធនាគារយោធា និងអ្នកផ្សាយវិទ្យុ លោកម៉ម សូណង់ដូ និងប្រធានសហជីព លោករ៉ុង ឈុន នៅមណ្ឌលអប់រំកែប្រែ( ម១) ដែលបានស្គាល់ជាទូទៅថា ពន្ធនាគារព្រៃសនោះ ។ លោកបានថ្លែងជាសាធារណៈស្ដីអំពី "រដ្ឋធម្មនុញ្ញ និងប្រជាធិបតេយ្យភាវូនីយកម្ម" នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។ លោកបានពិភាក្សា អំពីបញ្ហានានាដែលទាក់ទងនឹងរឿងដីធ្លី និងការគ្រប់គ្រងប្រព័ន្ធយុត្តិធម៌ជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា និងជួបជាមួយក្រុមសហគមន៍ផ្សេងៗនៅខេត្តកំពង់ស្ពឺ ។ លោកក៏បានចូលរួមឆ្លើយសំនួរក្នុងកម្មវិធីវិទ្យុសំរាប់ចាក់ផ្សាយក្នុងឱកាសប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ ។

៣. កំឡុងពេលបេសកកម្មរបស់លោក លោកតំណាងពិសេសបានស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្សទូទៅនៅក្នុងប្រទេសកម្ពុជា ។ លោកបានយកចិត្តទុកដាក់ជាពិសេសទៅលើរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា វិស័យយុត្តិធម៌ និង

នីតិរដ្ឋ សេរីភាពក្នុងការបង្កើតសមាគម ការជួបប្រជុំ និងការសំដែងមតិ បញ្ហាជីធ្លី និងតួនាទីអង្គការសង្គមស៊ីវិលនានា ក្នុងការលើកស្ទួយយុត្តិធម៌សង្គម ។

## I. វិធីសាស្ត្រ និង កិច្ចដំណើរការ

៤. ក្នុងការរៀបចំរបាយការណ៍លើកទី១របស់លោក ដើម្បីដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស លោកតំណាងពិសេស បានដាក់បញ្ចូលបញ្ហាសំខាន់ៗដែលចង្អុលបង្ហាញដោយគណៈកម្មការសិទ្ធិមនុស្ស តាមសេចក្តីសំរេចលេខ ២០០៥/៧៧ ។ ក្នុងការបំពេញភារកិច្ចតាមអាណត្តិរបស់ខ្លួន លោកតំណាងពិសេសមានចេតនារៀបចំរបាយការណ៍ ដោយផ្អែកលើរបាយការណ៍ និងអនុសាសន៍ផ្សេងៗ របស់លោកតំណាងពិសេសមុនៗ ដើម្បីធ្វើអត្ថាធិប្បាយដោយត្រង់ៗ និងប្រកបដោយន័យស្ថាបនាក្នុងការអភិវឌ្ឍន៍ និងដាក់ចេញជាអនុសាសន៍បន្ថែមទៀត ដើម្បីជួយដល់ប្រទេសកម្ពុជាក្នុងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពឆ្ពោះទៅកាន់សេចក្តីថ្លៃថ្នូរ និងសុខមាលភាពរបស់ប្រជាពលរដ្ឋកាន់តែប្រសើរ ។ លោកតំណាងពិសេសសង្ឃឹមថា របាយការណ៍នេះនឹងមិនត្រូវបានយល់ថា ជាការរិះគន់សំរាប់តែការរិះគន់នោះទេ ប៉ុន្តែត្រូវយល់ថាជាផ្នែកមួយនៃតួនាទីរបស់លោកតំណាងពិសេសក្នុងការផ្តល់យោបល់ដល់រាជរដ្ឋាភិបាល ពីវិធានការណ៍នានាដែលអាចធ្វើឡើង ដើម្បីលើកស្ទួយដល់ការអនុវត្តន៍សិទ្ធិមនុស្សតាមគោលការណ៍នីតិរដ្ឋ ។ លោកតំណាងពិសេសនឹងបំពេញទស្សនៈកិច្ចជាលើកទី២ មកកាន់ប្រទេសកម្ពុជានៅក្នុងខែមីនា ដើម្បីពិភាក្សាអំពីរបាយការណ៍នេះជាមួយរាជរដ្ឋាភិបាល មុនពេលលោកបង្ហាញអនុសាសន៍នេះជូនគណៈកម្មការសិទ្ធិមនុស្ស ។

៥. ក្នុងកំឡុងពេលបំពេញបេសកកម្មរបស់លោក លោកតំណាងពិសេសបានជួបជាក្រុម និងជាបុគ្គលមកពីផ្នែកផ្សេងៗជាច្រើននៃសង្គម ។ របាយការណ៍នេះក៏ឆ្លុះបញ្ចាំងពីសំឡេង និងសេចក្តីព្រួយបារម្ភទាំងឡាយរបស់ពួកគេផងដែរ ។ គឺវាប្រាកដហើយថា ប្រជាពលរដ្ឋកម្ពុជាប្រាថ្នាចង់បានយ៉ាងខ្លាំងនូវសិទ្ធិមនុស្ស និងយុត្តិធម៌ ។ សេចក្តីប្រាថ្នានេះ អាចជាការរំពឹងទុករបស់ប្រជាពលរដ្ឋដែលធ្លាប់ឆ្លងកាត់រយៈកាលដ៏គួរឱ្យរន្ធត់នៃការគ្រប់គ្រងរបស់ពួកខ្មែរក្រហម ដែលកាលនោះសិទ្ធិ និងសេរីភាពចម្បងៗបំផុតត្រូវបានបំបាត់ចោល ។ លោកតំណាងពិសេស មានសេចក្តីសប្បាយរីករាយនៅពេលដែលរដ្ឋមន្ត្រី និងមន្ត្រីរដ្ឋាភិបាលជាច្រើនដែលលោកបានជួប បានអះអាងថា រាជរដ្ឋាភិបាលមានឆន្ទៈឆ្ពោះទៅកាន់គោលដៅនេះដូចគ្នា ។

៦. ដោយសារនេះជារបាយការណ៍លើកដំបូងរបស់លោកដាក់ជូនគណៈកម្មការ លោកតំណាងពិសេស មានបំណងគូសបញ្ជាក់ពីកិច្ចដំណើរការដែលមានក្នុងអាណត្តិការងាររបស់លោក ។ ក្រោយពីរួចផុតពីជម្លោះដ៏តានតឹងមួយរយៈពេលកន្លងមកនេះ ប្រទេសកម្ពុជាគឺជាប្រទេសទី១ ក្នុងចំណោមប្រទេសជាច្រើនដែលអង្គការសហប្រជាជាតិ

និងអង្គការក្នុងតំបន់ផ្សេងៗជាច្រើនទៀត បានជួយសម្របសម្រួលដល់ការស្តារនីតិសម្បទារបស់រដ្ឋឡើងវិញ ។ ក្នុងករណីនីមួយៗ បញ្ហាសិទ្ធិមនុស្សដែលជាស្នូលនៃការធ្វើអោយមានស្ថេរភាព ប្រជាធិបតេយ្យភាវូនីយកម្ម និងយុត្តិធម៌ ត្រូវបានផ្តោតជាបញ្ហាអាទិភាពខ្ពស់ ។ ការការពារសិទ្ធិមនុស្សនៅប្រទេសកម្ពុជា និងការបញ្ចប់បញ្ហានិទណ្ឌភាព ចំពោះការរំលោភសិទ្ធិមនុស្សជាច្រើន បានធ្វើឱ្យមានការព្រួយបារម្ភជាចម្បងពីសហគមន៍អន្តរជាតិ ចាប់តាំងពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅឆ្នាំ១៩៩១មក ។ នៅក្នុងកិច្ចព្រមព្រៀងនេះ អាជ្ញាធរកម្ពុជាទាំងអស់ បានទទួលរ៉ាប់រងការពារសិទ្ធិមនុស្ស រួមមានទាំងសិទ្ធិរបស់ពលរដ្ឋក្នុងការការពារសិទ្ធិទាំងឡាយរបស់ពួកគេផង និងធានាថានយោបាយ និងកាអនុវត្តន៍ពីអតីតកាលនឹងមិនវិលត្រឡប់មកវិញឡើយ ។ ដោយកត់សំគាល់ឃើញថា "ប្រវត្តិសាស្ត្រថ្មីៗដ៏ជូរចត់របស់ប្រទេសកម្ពុជា តម្រូវឱ្យមានវិធានការពិសេសៗ ដើម្បីធានាដល់ការការពារសិទ្ធិមនុស្ស" កិច្ចព្រមព្រៀងក៏បានកំណត់បទបញ្ញត្តិពិស្តារមួយចំនួន សំរាប់បង្កើតឱ្យមានលទ្ធិប្រជាធិតេយ្យ និងការការពារសិទ្ធិមនុស្ស ។

៧. តាមបទពិសោធន៍នៃប្រទេសផ្សេងៗបង្ហាញថា មានហេតុផលដ៏ល្អដើម្បីគូសបញ្ជាក់ពីប្រជាធិបតេយ្យភាវូនីយកម្ម និងការការពារសិទ្ធិមនុស្ស ។ ភាពរីករាលជាច្រើនពីអតីតកាលនៅក្នុងប្រទេសផ្សេងៗ ដែលសហគមន៍អន្តរជាតិបានជួបប្រទះប្រហាក់ប្រហែលគ្នា ជាញឹកញាប់នោះ គឺលទ្ធផលនៃការបដិសេធន៍នៃសិទ្ធិចម្បងៗបំផុតរបស់ប្រជាពលរដ្ឋ និងការបដិសេធន៍មិនឱ្យពួកគេពាក់ព័ន្ធនឹងកិច្ចការនានារបស់រដ្ឋ ។ ប្រជាពលរដ្ឋដែលដក់ជាប់នូវសេចក្តីវេទនាទាំងនេះ ក៏ដូចជាអ្នកទាំងឡាយនៅប្រទេសកម្ពុជាដែរ ត្រូវការសន្តិសុខទាំងខាងផ្លូវកាយ និងផ្លូវចិត្ត ។ នៅពេលដែលសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋត្រូវបានរំលោភជាប្រចាំ គឺនៅពេលដែលពួកគេត្រូវបង្ខំឱ្យស្ថិតនៅក្រោមអំណាច ឬបង្ខំអោយសហការជាមួយរបបមួយដែលពួកគេភាគច្រើនបាត់បង់នូវការគោរពខ្លួនឯង ។ ពួកគេត្រូវការកសាងសេចក្តីទុកចិត្តជាមួយអ្នកដទៃ និងសហគមន៍ផ្សេងៗ ។ ជនរងគ្រោះនៃការអនុវត្តន៍អំណាចដោយមិនច្បាស់លាស់ និងតាមទំនើងចិត្ត ពួកគេត្រូវការប្រព័ន្ធមួយដែលការអនុវត្តន៍អំណាចរបស់រដ្ឋ អាចកំណត់ទុកជាមុនបានដោយស្របទៅនឹងច្បាប់សំរាប់គោលបំនងទាំងឡាយដែលអនុញ្ញាត ។ ពួកគេចាំបាច់ត្រូវទ្រាំទទួលយកនូវអំពើឃោរឃៅ និងអំពើក្បត់ផ្សេងៗសល់ពីអតីតកាល ។ អណត្តិអាជ្ញាបញ្ហាដាច់ខាតគឺជាការបង្កើនសេចក្តីទុកចិត្តចំពោះរដ្ឋាភិបាល ។ រដ្ឋាភិបាលត្រូវតែរៀបចំរចនាសម្ព័ន្ធ និងត្រូវបំពេញការងារតាមរបៀបបែបនេះ ដើម្បីអាចធ្វើឱ្យពួកគេអាចជឿទុកចិត្តបាន ។ ការរស់នៅក្រោមអំណាចផ្តាច់ការ ជាញឹកញាប់ធ្វើឱ្យប្រជាពលរដ្ឋបាក់ស្បាត និងខ្លបខ្លាច ។ រដ្ឋាភិបាលថ្មីត្រូវតែលើកទឹកចិត្តប្រជាពលរដ្ឋអោយសំដែងមតិ និងចូលរួមក្នុងកិច្ចការសាធារណៈ ។ រដ្ឋាភិបាល ត្រូវតែទទួលខុសត្រូវទៅលើពួកគេ ។ ព័ត៌មានស្តីពីគោលនយោបាយ និងសកម្មភាពនានារបស់រដ្ឋាភិបាលត្រូវតែផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានជ្រាប ។ ប្រជាពលរដ្ឋ និងសហគមន៍ទាំងអស់ ត្រូវបានរាប់អានស្មើៗគ្នា ជាពិសេស សិទ្ធិទទួលបានសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋាននៃជីវិត ហើយគ្មានសហគមន៍ណាមួយ គួរត្រូវបានបដិសេធពីឱកាស

ដើម្បីអភិវឌ្ឍន៍ ដោយសារតែសហគមន៍នោះមិនព្រមគាំទ្រផ្នែកនយោបាយដល់រដ្ឋាភិបាលនោះ អោយនៅកាន់អំណាចនោះទេ ។

៨. របបដែលប្រកាន់យកសិទ្ធិមនុស្ស ផ្តល់មូលដ្ឋាន និងគោលការណ៍ណែនាំមួយសំរាប់គោលដៅទាំងអស់នេះ រួមមានគោលការណ៍ជាមូលដ្ឋានសំរាប់ការរៀបចំរដ្ឋ និងរដ្ឋាភិបាល ។ ការទទួលខុសត្រូវជាបឋមរបស់រដ្ឋ គឺការលើកស្ទួយ និងការការពារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលសិទ្ធិទាំងអស់នេះបង្កើតបានជាក្របខ័ណ្ឌនៃគោលនយោបាយនានារបស់រដ្ឋ ។ ការចូលរួមពីប្រជាពលរដ្ឋ និងការផ្តល់អំណាចដល់ប្រជាពលរដ្ឋដែលកើតចេញពីការអនុវត្តន៍សិទ្ធិមនុស្ស និងបទដ្ឋានលទ្ធិប្រជាធិបតេយ្យ គឺជាតម្រូវការជាចំបងសំរាប់រយៈពេលក្រោយជម្លោះ ។ ការកសាងរដ្ឋ ត្រូវតែធ្វើឡើងដោយពួតដៃគ្នា ជាមួយការលើកស្ទួយសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ។ បើមិនដូច្នោះទេ អ្នកទាំងឡាយដែលតំណាងឱ្យរដ្ឋអាចអនុម័តយកយ៉ាងងាយស្រួលជាទីបំផុតនូវរបៀបគ្រប់គ្រងរបស់បុព្វាធិការីខ្លួន ដែលមានលក្ខណៈជិះជាន់សង្កត់សង្កិនជាមិនខាន ។

៩. សហគមន៍អន្តរជាតិដែលនៅតែចូលរួមក្រោយសម័យអន្តរកាលនោះ មានការទទួលខុសត្រូវជាពិសេសមួយ ដើម្បីធានាថា សិទ្ធិមនុស្សត្រូវបានគោរពតាមទាំងស្រុង ។ ការប្រឈមនោះ គឺត្រូវតាក់តែង និងអនុវត្តកម្មវិធីជំនួយផ្សេងៗ ដែលនឹងផ្តល់ផលប្រយោជន៍ដល់ប្រទេសកម្ពុជាទាំងមូល នឹងសម្របសម្រួលឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងការរៀបចំផែនការ និងការអនុវត្តន៍គំរោងអភិវឌ្ឍន៍ ហើយអនុញ្ញាតពួកគេអោយអនុវត្តសិទ្ធិនយោបាយ សិទ្ធិពលរដ្ឋ និងសិទ្ធិសេដ្ឋកិច្ចរបស់ពួកគេ ។ សំរាប់ហេតុផលនៃភាពត្រឹមត្រូវ និងប្រសិទ្ធិភាព សហគមន៍អន្តរជាតិបានធ្វើការយកចិត្តទុកដាក់ជាច្រើនក្នុងទសវត្សរ៍ចុងក្រោយនេះ ក្នុងការដាក់បញ្ចូលសិទ្ធិមនុស្ស ទៅក្នុងកម្មវិធីជំនួយអភិវឌ្ឍន៍របស់ខ្លួន ។ សហគមន៍អន្តរជាតិទទួលស្គាល់ថា សិទ្ធិមនុស្សទាំងអស់ប្រាស្រ័យគ្នាទៅវិញទៅមក ហើយទទួលស្គាល់ថា ការទទួលបានសិទ្ធិទាំងអស់ រួមទាំងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ គឺមានសារៈសំខាន់ណាស់ក្នុងការអនុវត្តន៍ លទ្ធិប្រជាធិបតេយ្យពិតប្រាកដ និងការអភិវឌ្ឍន៍មនុស្ស ។ យុទ្ធសាស្ត្រថ្មីនេះ ត្រូវបានយល់ឃើញយ៉ាងច្បាស់ នៅក្នុងឯកសារគោល នៃកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (យូអិនឌីភី) "ការធ្វើសមោហរណកម្មសិទ្ធិមនុស្សជាមួយការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាព" (ឆ្នាំ១៩៩៨) ដែលពិពណ៌នាអំពីការប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះសិទ្ធិ និងការអភិវឌ្ឍន៍ ។ ក្នុងក្របខ័ណ្ឌដ៏ទូលាយបែបនេះ ទោះបីជាមិនបាននិយាយដល់ក៏ដោយ ក៏វិស័យឯកជនត្រូវមានការទទួលខុសត្រូវក្នុងការគោរព និងអនុត្តន៍សិទ្ធិមនុស្សដែរ ។

## II. រដ្ឋធម្មនុញ្ញ

១០. តម្លៃទាំងនេះក៏ត្រូវបានឆ្លុះបញ្ចាំងទាំងស្រុងផងដែរនៅក្នុងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា ។រដ្ឋធម្មនុញ្ញនេះត្រូវបានអនុម័តនៅក្នុងឆ្នាំ១៩៩៣ ដោយសភាធម្មនុញ្ញដែលសមាជិកទាំងអស់ ត្រូវបានជ្រើសតាំងដោយសេរីតាមរយៈការបោះឆ្នោតក្រោមការជួយឧបត្ថម្ភពីអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (អ៊ុនតាក់) ដែលមានប្រជាពលរដ្ឋកម្ពុជាបានចូលរួមយ៉ាងច្រើនកុះករ ។ ការព្រាង និងការអនុម័តរដ្ឋធម្មនុញ្ញគឺជាការទទួលខុសត្រូវទាំងស្រុងរបស់ប្រជាពលរដ្ឋកម្ពុជា ។ ដូច្នេះ រដ្ឋធម្មនុញ្ញនេះឆ្លុះបញ្ចាំងពីតម្លៃ និងគោលបំណងជាច្រើនដែលប្រជាពលរដ្ឋកម្ពុជាបានប្តេជ្ញាចិត្តដោយខ្លួនគេ ។ រដ្ឋធម្មនុញ្ញនេះ មានបំណងធ្វើជានិមិត្តរូបនៃការចាប់កំណើតឡើងវិញរបស់ជាតិ និងរដ្ឋ ។ រដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូល ហើយច្បាប់ និងគោលនយោបាយទាំងឡាយណាដែលមិនស្របតាមរដ្ឋធម្មនុញ្ញនេះ ត្រូវចាត់ទុកជាមោឃៈ ។ តម្លៃជាស្នូលនៃរដ្ឋធម្មនុញ្ញនេះ គឺលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្សនិងសិទ្ធិមនុស្ស ។ ប្រជាពលរដ្ឋពេញវ័យគ្រប់រូបមានសិទ្ធិបោះឆ្នោត ដើម្បីជ្រើសរើសតំណាងទាំងឡាយរបស់ពួកគេ ហើយអង្គនីតិបញ្ញត្តិ អាចទំលាក់អង្គនីតិប្រតិបត្តិបាន ប្រសិនបើខ្លួន បាត់បង់ជំនឿទុកចិត្តទៅលើអង្គនីតិប្រតិបត្តិនេះ ។ សិទ្ធិមនុស្សភាគច្រើន ដូចជាសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ដូចជាសិទ្ធិសេដ្ឋកិច្ច និងសង្គម ត្រូវបានដាក់បញ្ចូលទៅក្នុងរដ្ឋធម្មនុញ្ញ ហើយអនុវត្តន៍អោយបានខ្ជាប់ខ្ជួនទៅតាម សន្ធិសញ្ញាអន្តរជាតិសំខាន់ៗស្តីពីសិទ្ធិមនុស្ស ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ។ រដ្ឋធម្មនុញ្ញតំកល់សេរីភាពក្នុងការសំដែងមតិ សិទ្ធិក្នុងការបង្កើតសមាគម និងការជួបប្រជុំ និងសិទ្ធិក្នុងការចូលរួមផ្សេងៗទៀត ។ រដ្ឋធម្មនុញ្ញផ្តល់ការការពារដល់សហជីព និងអង្គការសង្គមស៊ីវិលនានា ។ គោលការណ៍គ្រឹះដែលស្របនឹងគោលការណ៍នៃរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ គឺសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ព្រមទាំងនីតិវិធីដើម្បីអនុវត្តគោលការណ៍ទាំងនេះ ដែលគោលការណ៍ទាំងនេះ មិនអាចត្រូវបានលប់ចោល និងធ្វើវិសោធនកម្មឡើយ ។ ទន្ទឹមនឹងនោះមានគោលការណ៍អមមួយ គឺគោលការណ៍នៃការបែងចែកអំណាច ដើម្បីឱ្យស្ថាប័ននីមួយៗរបស់រដ្ឋ មានសេរីភាពក្នុងដែនអំណាចរបស់ខ្លួន ជាពិសេសស្ថាប័នតុលាការដែលឯករាជ្យភាពរបស់ខ្លួន ត្រូវបានការពារតាមរយៈបទបញ្ញត្តិផ្សេងៗ ។ រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា មានចែងយ៉ាងច្បាស់ថា អំណាចនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ ត្រូវចែកដាច់ពីគ្នា ។ មាត្រា១២៨ ចែងថា "អំណាចតុលាការជាអំណាចឯករាជ្យ" និងមាត្រា១៣០ ចែងច្បាស់ទៀតថា "គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬអំណាចនីតិប្រតិបត្តិអាចទទួលអំណាចតុលាការអ្វីបានឡើយ" ។

១១. រដ្ឋធម្មនុញ្ញចែងអំពីក្របខ័ណ្ឌដ៏ល្អមួយសំរាប់រដ្ឋាភិបាលបែបប្រជាធិបតេយ្យ មានប្រសិទ្ធភាព និងមានការទទួលខុសត្រូវ ក៏ដូចជាចំនុចចាប់ផ្តើមដ៏មានតម្លៃមួយសំរាប់សិទ្ធិមនុស្ស ។ ទោះបីយ៉ាងណាក៏ដោយ ក៏លោក

តំណាងពិសេសមានការព្រួយបារម្ភអំពីមធ្យោបាយដែលស្ថាប័នមួយចំនួនត្រូវបានបង្កើតឡើងតាមរដ្ឋធម្មនុញ្ញដើម្បីលើកកំពស់នីត្យានុកូលភាព និងសិទ្ធិមនុស្ស ត្រូវបានធ្វើអោយទៅជារឿងនយោបាយ និងអព្យាក្រិតភាព។ បញ្ហាជាច្រើនដែលបង្កការរំខានដល់លោកតំណាងពិសេស ជាទូទៅគឺបញ្ហាកើតមានទៅលើបុគ្គល និងក្រុមដែលលោកបានជួប នៅប្រទេសកម្ពុជា។ បញ្ហានេះ កើតចេញពីការខកខានមិនបានអនុវត្តតាមរដ្ឋធម្មនុញ្ញ អោយបានពេញលេញ។ ដោយផ្ទុយទៅនឹងឋានៈជាផ្លូវការនៃស្ថាប័នចំបងទាំងបួនដែលបង្កើតឡើងសំរាប់ការពាររដ្ឋធម្មនុញ្ញ និងតម្លៃរបស់វាជាមួយប្រសិទ្ធភាពនៃការអនុវត្តន៍ជាក់ស្តែងរបស់ស្ថាប័នទាំងនោះ គេមានភស្តុតាងបង្ហាញយ៉ាងច្បាស់ថា រដ្ឋធម្មនុញ្ញមិនត្រូវទទួលបានការគោរពទាំងស្រុងនោះទេ។

## III. **ការការពាររដ្ឋធម្មនុញ្ញ**

### *ក- របបរាជានិយម*

១២. ទោះបីជារដ្ឋធម្មនុញ្ញចែងអំពីរដ្ឋាភិបាលអាស្រ័យប្រព័ន្ធសភានិយមក៏ដោយក៏តួនាទីដ៏សំខាន់ត្រូវបានថ្វាយជូនព្រះមហាក្សត្រ ក្នុងការធានាឱ្យមានការគោរពរដ្ឋធម្មនុញ្ញ និងឯករាជ្យភាពរបស់តុលាការ។ មាត្រា៨ ទទួលស្គាល់ឋានៈរបស់ព្រះមហាក្សត្រថាជា" និម្មិតរូបនៃឯកភាពជាតិ និងនិរន្តភាពជាតិ"។ មាត្រានេះចែងថា ព្រះមហាក្សត្រទ្រង់ជា" អ្នកធានាឯករាជ្យជាតិ អធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ជាអ្នកធានាការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋគ្រប់រូប និងការគោរពសន្ធិសញ្ញាអន្តរជាតិ"។ ព្រះមហាក្សត្រទ្រង់មាន" តួនាទីដ៏ខ្ពង់ខ្ពស់ជាអាជ្ញាកណ្តាល ដើម្បីធានាការប្រព្រឹត្តទៅនៃអំណាចសាធារណៈឱ្យបានទៀងទាត់" (មាត្រា៩)។ ព្រះមហាក្សត្រទ្រង់មានអំណាចពិសេស ដើម្បីទ្រង់អាចបំពេញភារកិច្ចទាំងនេះបាន។ ទ្រង់អាចទាក់ទងជាមួយសភាជាតិ មានតួនាទីក្នុងការតែងតាំងនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រី មានសិទ្ធិទទួលព័ត៌មានពីរាជរដ្ឋាភិបាលអំពីកិច្ចការរដ្ឋ ទ្រង់គឺជាមេបញ្ជាការកំពូលនៃកងយោធាខេមរភូមិន្ទ និងគង់ជាអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ និងនៅពេលប្រជាជាតិប្រឈមមុខគ្រោះថ្នាក់ ព្រះមហាក្សត្រទ្រង់ប្រកាសប្រទានដំណឹងជាសាធារណៈដាក់ប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ក្រោយពីបានមតិឯកភាពពីនាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា និងប្រធានព្រឹទ្ធសភា។ ប្រសិនបើព្រះមហាក្សត្រទ្រង់ព្រះរាជតំរិះថា ច្បាប់ណាមួយមិនស្របរដ្ឋធម្មនុញ្ញ ទ្រង់អាចដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមើលពីធម្មនុញ្ញភាពនៃច្បាប់នោះ។ ព្រះមហាក្សត្រទ្រង់មានការទទួលខុសត្រូវជាពិសេសចំពោះឯករាជ្យភាពរបស់តុលាការ ហើយទ្រង់គង់ជាព្រះអធិបតីនៃឧត្តមប្រឹក្សានៃអង្គចៅក្រមដែលត្រូវជួយព្រះមហាក្សត្រក្នុងការធានាឱ្យមានឯករាជ្យភាពតាមរយៈនីតិវិធីនៃការតែងតាំង ការដាក់វិន័យ និងការដកហូតមុខតំណែងចៅក្រម និងព្រះរាជអាជ្ញា។

១៣.	អាស្រ័យហេតុនេះ គឺវាប្រាកដណាស់ថា ព្រះមហាក្សត្រទ្រង់ជាមហាក្សត្រលើសពី "របបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ"ទៅទៀត នេះគឺជាវាក្យស័ព្ទដែលគេយល់ឃើញជាទូទៅ ។ ព្រះអង្គត្រូវបានតម្រូវឱ្យធ្វើអន្តរាគមន៍ក្នុងកិច្ចការរដ្ឋ នៅពេលដែលរដ្ឋធម្មនុញ្ញ សិទ្ធិរបស់បុគ្គលនិងសហគមន៍ ឬឯករាជ្យភាពរបស់តុលាការ និងព្រះរាជអាជ្ញា ត្រូវបានគំរាមកំហែង ឬរំលោភ ។ ព្រះមហាក្សត្រ ទ្រង់មិនគ្រាន់តែជាព្រះមហាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញ ដែលត្រូវតែអនុវត្តតាមសេចក្តីណែនាំរបស់រដ្ឋាភិបាល ឬត្រូវបានគំរាមដកពីបល្ល័ង្កប្រសិនបើទ្រង់មិនធ្វើតាមនោះទេ ។ បើមិនដូច្នេះទេ ការការពាររដ្ឋធម្មនុញ្ញដ៏ចម្បងនឹងមិនមានប្រសិទ្ធភាពឡើយ ។

## *ខ- ក្រុមប្រឹក្សាធម្មនុញ្ញ*

១៤.	ជំពូក១២ នៃរដ្ឋធម្មនុញ្ញមានចែងអំពីក្រុមប្រឹក្សាធម្មនុញ្ញ ។ ក្រុមប្រឹក្សានេះមិនស្ថិតនៅជាមួយប្រព័ន្ធ និងឋានានុក្រមតុលាការដែលត្រូវបានកំណត់ដោយឡែកនៅក្នុងជំពូក១១ នៃរដ្ឋធម្មនុញ្ញនោះទេ ។ ដោយរួមជាមួយសមត្ថកិច្ចក្នុងការត្រួតពិនិត្យពីធម្មនុញ្ញភាពនៃច្បាប់ និងវិនិច្ឆ័យលើវិវាទស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងព្រឹទ្ធសភា ក្រុមប្រឹក្សានេះគឺជាអង្គការនិយតកម្មមួយ ដែលត្រូវបានបង្កើតឡើងដើម្បីធានាដល់ការប្រព្រឹត្តទៅនៃអំណាចទាំងបីឱ្យបានរលូន ។ តួនាទីរបស់ក្រុមប្រឹក្សាក្នុងការធានាអោយច្បាប់នានាស្របតាមរដ្ឋធម្មនុញ្ញ គឺជាតួនាទីសំខាន់ណាស់ដើម្បីបញ្ជាក់ថារដ្ឋធម្មនុញ្ញគឺជាច្បាប់កំពូល ។ មាត្រា១៣៦ ចែងយ៉ាងច្បាស់ថា " ក្រុមប្រឹក្សាធម្មនុញ្ញមានភារកិច្ចការពារ ការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់នានា ដែលបានអនុម័តដោយរដ្ឋសភា និងត្រួតពិនិត្យដោយព្រឹទ្ធសភា" ។ ប្រសិនបើច្បាប់ណាមួយត្រូវបានប្រកាសថាមិនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់នោះលែងមានប្រសិទ្ធភាពទៀតហើយ ។ ក្រុមប្រឹក្សាធម្មនុញ្ញរំលឹកពីភាពខុសប្លែកគ្នាមួយចំនួន ជាមួយក្រុមប្រឹក្សាធម្មនុញ្ញបារាំង តាមវិធីច្រើនយ៉ាង រួមមានអាណត្តិត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ក្រោយពីច្បាប់នោះចូលជាធរមាន និងអាណត្តិបើកសវនាការជាសាធារណៈចំពោះរឿងក្តីពាក់ព័ន្ធនឹងការបោះឆ្នោតជាសកល ។ ក្រុមប្រឹក្សានេះមានសមាជិកចំនួន៩រូប ដែលត្រូវតែឯករាជ្យ និងមិនជាប់ពាក់ព័ន្ធជាមួយរដ្ឋាភិបាល អង្គការនីតិបញ្ញត្តិ ឬតុលាការ ឬក៏មានតួនាទីខ្ពង់ខ្ពស់ណាមួយនៅក្នុងគណៈបក្សនយោបាយ ឬសហជីពណាមួយឡើយ( មាត្រា១៣៩) ។ សមាជិកចំនួន៣រូប ត្រូវបានតែងតាំងដោយព្រះមហាក្សត្រ ៣រូបតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង៣រូបទៀតបោះឆ្នោតជ្រើសតាំងដោយសភាជាតិ ។ បច្ចុប្បន្ននេះ សមាជិកចំនួន៦រូប ក្នុងចំណោមសមាជិកទាំង៩រូប ជាប់ពាក់ព័ន្ធនឹងគណៈបក្សប្រជាជនកម្ពុជា ដែលនេះបង្កើតឱ្យមានជាបញ្ហាអនាគតិនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ជាអកុសល កំឡុងពេលបេសកកម្មរបស់លោក លោកតំណាងពិសេសមិនអាចជួបពិភាក្សាជាមួយក្រុមប្រឹក្សាធម្មនុញ្ញបានទេ ប៉ុន្តែលោកសង្ឃឹមថា នឹងបានជួបក្រុមប្រឹក្សានេះ នៅពេលដែលលោកធ្វើទស្សនៈកិច្ចលើកក្រោយ ។

## គ-	ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

១៥.	ចាប់ពីមាត្រា១៣២ ដល់ ១៣៤ រដ្ឋធម្មនុញ្ញប្រគល់ភារកិច្ចក្នុងការធានាឯករាជ្យភាពរបស់តុលាការ និង ការដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា ថ្វាយព្រះមហាក្សត្រ ដោយមានជំនួយពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានអំណាចតែងតាំង ផ្លាស់ប្តូរ និងដាក់វិន័យចៅក្រម និងព្រះរាជអាជ្ញា ។ ទោះបីជាច្បាប់ត្រូវបានអនុម័ត នៅក្នុងឆ្នាំ១៩៩៤ ដើម្បីបង្កើតឧត្តមប្រឹក្សានេះក៏ដោយ ក៏បញ្ហាខ្វែងគំនិតគ្នាស្តីពីសមាជិកភាពនៃឧត្តមក្រុមប្រឹក្សា នេះបានពន្យាពេលដល់ការបង្កើតក្រុមប្រឹក្សានេះ ហើយចាប់តាំងពីពេលនោះមក ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនបានបំពេញតួនាទីរបស់ខ្លួនតាមរដ្ឋធម្មនុញ្ញ ជាស្ថាប័នមួយឯករាជ្យទទួលខុសត្រូវក្នុងការតែងតាំង ការផ្លាស់ប្តូរ និង ការដាក់វិន័យចៅក្រមនោះទេ ។

១៦.	ព្រះមហាក្សត្រទ្រង់ជាអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលមានសមាជិកជារដ្ឋមន្ត្រីក្រសួង យុត្តិធមិ ប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រធាន សាលាឧទ្ធរណ៍ និងចៅក្រមចំនួន៣រូបដែលបោះឆ្នោតជ្រើសតាំងដោយចៅក្រម ។ សមាជិកទាំងអស់នៃក្រុមប្រឹក្សា នេះ លើកលែងតែម្នាក់ប៉ុណ្ណោះ ជាសមាជិករបស់គណៈបក្សប្រជាជនកម្ពុជា ហើយមានសមាជិក២រូបក្នុងចំណោម នោះ ជាសមាជិកគណៈកម្មាធិការកណ្តាលរបស់បក្ស ។ ចំពោះបញ្ហាសម្រេចដាក់វិន័យ ឧត្តមក្រុមប្រឹក្សានៃអង្គ ចៅក្រមបង្កើតគណៈកម្មាធិការវិន័យដាច់ដោយឡែកពីគ្នាសំរាប់ចៅក្រម ដែលដឹកនាំដោយប្រធានតុលាការកំពូល និងសំរាប់ព្រះរាជអាជ្ញា ដែលដឹកនាំដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។ គណៈកម្មាធិការវិន័យទាំងនេះ បានអនុម័តបញ្ញាផ្ទៃក្នុង និងបទបញ្ជាផ្សេងៗ ប៉ុន្តែបទបញ្ញត្តិទាំងនេះមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈឡើយ ។

១៧.	សេចក្តីព្រាងច្បាប់ ដើម្បីធ្វើវិសោធនកម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានបំណងបង្កើតឱ្យ មានលេខាធិការដ្ឋានមួយសំរាប់ក្រុមប្រឹក្សានេះក្នុងការបំពេញការងារឱ្យកាន់តែមានប្រសិទ្ធភាព ។ កាលពីថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៥ លោកនាយករដ្ឋមន្ត្រីបានចេញអនុក្រិត្យមួយរំលាយលេខាធិការដ្ឋាននេះ ហើយប្រគល់មុខ ងារនៃលេខាធិការដ្ឋានឱ្យទៅក្រសួងយុត្តិធម៌វិញ ។ តាមប្រសាសន៍លោកនាយករដ្ឋមន្ត្រី លេខាធិការដ្ឋាននេះត្រូវ បានរំលាយ ដោយសារតែការខកខានមិនបានចាត់ការអោយមានប្រសិទ្ធិភាព ចំពោះបណ្តឹងជាច្រើនដែលប្តឹងចៅ ក្រម និងព្រះរាជអាជ្ញា ។ ទោះបីយ៉ាងណាក៏ដោយ វាអាចនឹងស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ បើសិនជាលេខាធិការ ដ្ឋាននេះត្រូវបានពង្រឹង ជាជាងផ្លាស់ប្តូរមុខងាររបស់លេខាធិការដ្ឋានទៅឱ្យក្រសួងយុត្តិធមិដែលជាផ្នែកមួយរបស់ រដ្ឋាភិបាលនោះ ។ លោកព្រះរាជអាជ្ញាមួយចំនួនបានជម្រាបលោកតំណាងពិសេសថា ឧត្តមក្រុមប្រឹក្សានេះមិនបាន ការពារដល់ឯករាជ្យភាពរបស់ពួកគេ ឬរបស់ចៅក្រមឡើយ (សូមអានផ្នែកខាងក្រោម) ។ មាននិន្នាការមួយនៅ

ក្នុងរដ្ឋាភិបាលក្នុងការប្រើប្រាស់ព្រះមហាក្សត្រ ក្នុងឋានៈទ្រង់ធ្វើជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ថាជាអ្នកប្រថាប់ត្រា ជាជាងអ្នកធ្វើសេចក្តីសម្រេចពិតៗ តាមរដ្ឋធម្មនុញ្ញនោះ។

*ឃ- សមាជជាតិ*

១៨. រដ្ឋធម្មនុញ្ញបង្កើតឱ្យមានសមាជជាតិ ដែលជានិមិត្តរូបនៃការប្រមូលផ្តុំប្រជាពលរដ្ឋ ដើម្បីធ្វើការសន្ទនាជាមួយរដ្ឋាភិបាល និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល ចំពោះមុខប្រជាពលរដ្ឋខ្លួន។ សមាជជាតិប្រជុំមួយដងក្នុងមួយឆ្នាំ តាមការកោះអញ្ជើញរបស់នាយករដ្ឋមន្ត្រី ហើយព្រះមហាក្សត្រទ្រង់ធ្វើជាព្រះអធិបតី។ យោងតាមរដ្ឋធម្មនុញ្ញ គោលបំណងនៃសមាជជាតិ គឺ "ដើម្បីផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋឱ្យបានជ្រាបដោយផ្ទាល់អំពីកិច្ចការផ្សេងៗដែលជាប្រយោជន៍ជាតិ និងដើម្បីឱ្យពួកគេលើកបញ្ហា និងសំណូមពរជូនរដ្ឋអំណាចដោះស្រាយ" (មាត្រា ១២៨ចាស់)។ សមាជជាតិ មានអំណាចអនុម័តអនុសាសន៍ផ្សេងៗជុនអាជ្ញាធររដ្ឋ និងរដ្ឋសភា ធ្វើការពិចារណា។ លោកតំណាងពិសេសបានត្រូវគេប្រាប់ថា លោកនាយករដ្ឋមន្ត្រីមិនបានកោះប្រជុំសមាជជាតិម្តងណាទេ ចាប់តាំងពីរដ្ឋធម្មនុញ្ញត្រូវបានអនុម័ត។ ដូច្នេះ ឱកាសដ៏មានតម្លៃដែលផ្នែកផ្សេងៗរបស់សង្គមអាចជួបគ្នា ដើម្បីពិភាក្សាអំពីបញ្ហាជាតិ និងដើម្បីសន្ទនាជាមួយរដ្ឋាភិបាលត្រូវបានបាត់បង់ នៅពេលដែលទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋាភិបាលបានក្លាយទៅជាបញ្ហាចោទដ៏ធ្ងន់ធ្ងរនោះ។

## IV. **វិស័យយុត្តិធម៌ និងនីតិរដ្ឋ**

១៩. កំឡុងពេលបេសកកម្មរបស់លោក លោកតំណាងពិសេសមានឱកាសពិភាក្សាអំពីស្ថានភាពប្រព័ន្ធតុលាការកម្ពុជា និងអំពីកិច្ចខិតខំប្រឹងប្រែងនានាដែលកំពុងតែធ្វើ ដើម្បីបំពេញចន្លោះប្រហោងច្បាប់ និងដើម្បីបង្កើតស្ថាប័នរដ្ឋដ៏រឹងមាំក្នុងការពារសិទ្ធិមនុស្ស និងសេរីភាពនានាដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ។

*ក- បញ្ហានិទណ្ឌភាព*

២០. នៅក្នុងរបាយការណ៍របស់លោក ដែលបានដាក់ជូនសម័យប្រជុំលើកទី៦១ នៃគណៈកម្មការសិទ្ធិមនុស្ស អតីតតំណាងពិសេស លោកភិធីរ លយប្រែកត៍ បានរាយការណ៍ថា "បញ្ហានិទណ្ឌភាព គឺជាបុព្វហេតុ និងលទ្ធផលដ៏ចម្បង ដែលបង្កឱ្យមានបញ្ហាសិទ្ធិមនុស្សជាច្រើននៅកម្ពុជា" (E/CN.4/2005/116, para. 26)។ លោកបានអំពាវនាវឱ្យធ្វើការវិភាគពីការវិវត្តន៍នានា ចាប់តាំងពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅឆ្នាំ១៩៩១មក។ ដើម្បីជាការចូលរួមចំណែកក្នុងការធ្វើវិភាគនេះ លោកអតីតតំណាងពិសេស បានបញ្ចប់របាយការណ៍ស្តីពីលំនាំនៃបញ្ហានិទណ្ឌភាពដែលកំពុងកើតមានជាបន្តនៅកម្ពុជា កាលពីខែតុលា ឆ្នាំ២០០៥ មុនពេលបញ្ចប់អាណត្តិរបស់លោក។ របាយការណ៍នេះតាមដាននូវទម្រង់ និងបែបផែននានានៃបញ្ហានិទណ្ឌភាពក្នុងរយៈពេលជាច្រើនឆ្នាំ ចាប់តាំងពី

កិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស ត្រូវបានកត់ត្រាចូលទៅក្នុងរបាយការណ៍នានារបស់លោកតំណាងពិសេសទាំងអស់ និងអ្នកជំនាញការផ្សេងៗទៀត ដែលធ្វើការក្រោមជំនួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ ។ អតីតតំណាងពិសេស លោកម៉ៃឃើល ឃើប៊ី និងលោកថូម៉ាស់ ហាំម៉ាប៊ើក បានយល់ស្របទាំងស្រុងលើរបាយការណ៍នេះ ពីព្រោះរបាយការណ៍នេះទាក់ទងនឹងការស៊ើបអង្កេត ការស្វះស្វែងរក និងអនុសាសន៍នានា ដែលលោកទាំងពីរបានធ្វើឡើង ក្នុងកំឡុងអាណត្តិការងាររបស់លោក ។ ផ្នែកខាងក្រោមនេះ គឺជាផ្នែកដែលបានដកស្រង់ចេញពីរបាយការណ៍នេះ ។

២១. ធាតុផ្សំជាច្រើននៃបញ្ហានិទណ្ឌភាពដែលចេះតែបន្ត ដែលបានគូសបញ្ជាក់នៅក្នុងរបាយការណ៍នេះត្រូវបានរាយការណ៍ដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជានៅក្នុងឆ្នាំ១៩៩៣ ។ អ៊ុនតាក់បានធ្វើរបាយការណ៍ថា ខ្លួនបានរកឃើញសង្គមមួយដែលខ្វះស្ថាប័នជាមូលដ្ឋាន និងកិច្ចដំណើរការនានា សំរាប់ជាការពុំនាក់អាស្រ័យក្នុងការគោរពសិទ្ធិមនុស្ស ។ ស្ថាប័នដែលមានស្រាប់ ត្រូវបានដឹកនាំឆ្ពោះទៅកាន់ការគ្រប់គ្រងនយោបាយតឹងរឹងតាមបែបរដ្ឋផ្តាច់ការ ដែលគាំទ្រដោយកំលាំងយោធាសកម្ម ហើយគ្មានឆន្ទៈសំរុះសំរួលជាមួយប្រភពអំណាចផ្សេងៗទៀតឡើយ ។ រចនាសម្ព័ន្ធច្បាប់ និងស្ថាប័ននានាដែលមានស្រាប់ គឺសុទ្ធតែជារចនាសម្ព័ន្ធ ដែលបានបង្កើតឡើងកាលពីជាងមួយទសវត្សមុននេះ ។ មិនមានអត្ថបទច្បាប់គ្រប់គ្រាន់ ឬគ្មានអត្ថបទច្បាប់សោះតែម្តង សូមបីតែច្បាប់រដ្ឋប្បវេណី កិច្ចសន្យានិងទ្រព្យសម្បត្តិ ច្បាប់ព្រហ្មទណ្ឌនិងនីតិវិធីព្រហ្មទណ្ឌ វិធាននានាសំរាប់តុលាការ ភស្តុតាង ឬច្បាប់ការងារ ។ ស្ថាប័នដទៃទៀត ដូចជា នគរបាល និងតុលាការ មិនទាន់រៀបចំឱ្យបានពេញលេញ ឬដំណើរការឱ្យបានត្រឹមត្រូវនៅឡើយ ។ អ៊ុនតាក់បានវាយតំលៃបញ្ហាយុត្តិធម៌មិនជាមូលដ្ឋាន ថាជាការខូចខាតទាំងស្រុងនៅក្នុងប្រព័ន្ធច្បាប់ ។ អ៊ុនតាក់បានធ្វើសេចក្តីព្រាងច្បាប់ព្រហ្មទណ្ឌអន្តរកាលមួយ ដែលជាវិធានការសំរាប់បិទភ្ជិតចន្លោះប្រហោងនេះ ហើយរំពឹងថានៅពេលដ៏ខ្លីខាងមុខ ច្បាប់នេះនឹងត្រូវដាក់ជំនួសដោយច្បាប់មួយទៀត ដែលមានលក្ខណៈអចិន្ត្រៃយ៍ជាង ។

២២. ដើមឡើយ អ៊ុនតាក់បានព្យាយាមបញ្ចុះបញ្ចូលអាជ្ញាធរកម្ពុជា ឱ្យស៊ើបអង្កេតពីការចោទប្រកាន់អំពីការរំលោភសិទ្ធិមនុស្សនានា និងអោយធ្វើការចោទប្រកាន់ ជនទាំងឡាយណាដែលទទួលខុសត្រូវ ពីការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរនេះ ទៅតុលាការ ។ ក្នុងខណៈដែលមានប្រសិទ្ធិភាពនៅក្នុងករណីតូចតាចមួយចំនួន អ៊ុនតាក់សង្កេតឃើញមាន "ភាពអល់អែក" ក្នុងការចាត់វិធានការទៅលើមន្ត្រីជាន់ខ្ពស់ ហើយជាពិសេស ការចាត់វិធានការលើករណីពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សផ្សេងៗ ។ នៅក្នុងករណីទាំងនេះ អាជ្ញាធររដ្ឋបាលបានធ្វើការបដិសេធមិនព្រមធ្វើការស៊ើបអង្កេត ហើយមន្ត្រីជាន់ខ្ពស់បានសំដែងមតិថា ពួកគេមិនមានសមត្ថកិច្ចទាំងក្នុងការស៊ើបអង្កេត ទាំងក្នុងការចោទប្រកាន់លើបញ្ហាទាំងនេះទេ ។ ខណៈដែលច្បាប់អ៊ុនតាក់បានចែងអំពីក្របខ័ណ្ឌផ្លូវការមួយក្នុងការ

ដោះស្រាយបញ្ហានេះ វាបង្ហាញឱ្យឃើញកាន់តែច្បាស់ថា ក្នុងការអនុវត្តន៍ជាក់ស្តែង បទល្មើសទាំងនេះមិនអាចធ្វើការចោទប្រកាន់ដោយរដ្ឋអាជ្ញា ដែលបានប្រឈមមុខ មិនត្រឹមតែចំពោះការគំរាមកំហែងដោយការជ្រៀតជ្រែកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំឱ្យគ្រោះថ្នាក់ដល់រូបកាយ កាលបើលោករដ្ឋអាជ្ញាតាំងខ្លួនជាដើមបណ្តឹងអាជ្ញា ផ្ទុយទៅនឹងឆន្ទៈរបស់អាជ្ញាធរនយោបាយនានានោះ ។

២៣. អ៊ុនតាក់បានបង្កើតការិយាល័យរដ្ឋអាជ្ញាពិសេសមួយ នៅក្នុងខែមករា ឆ្នាំ១៩៩៣ ដោយសង្ឃឹមថា ប្រសិនបើការិយាល័យនេះដំណើរការនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ដោយសារចរិតសាធារណៈនៃការចោទប្រកាន់ ការិយាល័យនេះអាចដើរតួនាទីក្នុងការកែប្រែ "វប្បធម៌" ច្បាប់ និងមន្ត្រីតុលាការបាន ។ ប៉ុន្តែវាបានបង្ហាញពីការដែលមិនអាចធ្វើទៅបាន ហើយអ៊ុនតាក់ត្រូវតែទទួលស្គាល់ថា ខ្លួនមិនអាចចាត់ការករណីទាំងឡាយដែលជាប់ពាក់ព័ន្ធនឹងរឿងនយោបាយនៅក្នុងតុលាការកម្ពុជាបានឡើយ ។ សមាសភាពនៃរដ្ឋបាល ជាពិសេសកងកំលាំងសន្តិសុខ មានការជាប់ពាក់ព័ន្ធនៅក្នុងអំពើហឹង្សានយោបាយ ។ នេះមានន័យថា តុលាការមិនត្រូវបានអនុញ្ញាតឱ្យដំណើរការដោយឯករាជ្យ ឬមិនលំអៀងនោះទេ ។ ច្បាប់ និងតុលាការនិយាយដោយឡែក នៅតែបានត្រូវចាត់ទុកជាឧបករណ៍របស់គណៈបក្សនយោបាយកំពុងកាន់អំណាចដដែល ។

២៤. នៅក្នុងរបាយការណ៍លើកដំបូងរបស់លោក ដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស នាសម័យប្រជុំលើកទី៥០ អតីតលោកតំណាងពិសេស **ម៉ៃឃើល យ៉ីឃឺ** បានកំណត់ក្នុងរបៀបវារៈសំរាប់ការកែប្រែ (E/CN.4/1994/73) ។ លោកបានទទូចឱ្យបង្កើតក្រុមប្រឹក្សាធម្មនុញ្ញ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឱ្យបានឆាប់រហ័ស ។ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាត្រូវតែមានអោយបានឆាប់ ។ ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីវិធាននៃភស្តុតាង និងក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ត្រូវតែពិនិត្យឡើងវិញ ដើម្បីឱ្យស្របនឹងរដ្ឋធម្មនុញ្ញថ្មី ។ ច្បាប់ទាំងអស់នេះជាតំរូវការចាំបាច់ក្នុងការបង្កើតមូលដ្ឋានគតិយុត្តិរួមមួយ សំរាប់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ការងារនគរបាល កិច្ចដំណើរការរបស់តុលាការ និងសិទ្ធិរបស់ជនជាប់ចោទ ។ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់តុលាការ និងការរៀបចំរចនាសម្ព័ន្ធនៃប្រព័ន្ធតុលាការឡើងវិញ គឺជាសេចក្តីត្រូវការដើម្បីបង្កើត និងបញ្ជាក់ឱ្យច្បាស់ពីយុត្តាធិការរបស់តុលាការគ្រប់កំរិត ។ អតីតលោកតំណាងពិសេស **ម៉ៃឃើល យ៉ីឃឺ** ក៏បានគូសបញ្ជាក់ផងដែរថា សិទ្ធិទាំងឡាយដែលត្រូវបានការពារជាផ្លូវការនៅក្នុងរដ្ឋធម្មនុញ្ញថ្មី នឹងមិនមានការគ្រប់គ្រងវាទេ ប្រសិនបើគ្មានការអនុម័តច្បាប់សំរាប់អនុវត្តសិទ្ធិទាំងនោះ ។ ប្រសិនបើសិទ្ធិជាមូលដ្ឋាននៅក្នុងរដ្ឋធម្មនុញ្ញត្រូវបានគេគោរព ប្រទេសកម្ពុជា ចាំបាច់ត្រូវធ្វើឱ្យច្បាប់របស់ខ្លួនភាគច្រើនមានភាពស្អាតស្អំ និងមានប្រសិទ្ធិភាពចំពោះច្បាប់ដែលមានស្រាប់ និងចំពោះការអនុវត្តន៍កន្លងមកដែលនាំឱ្យមានបញ្ហានិទណ្ឌភាពកើតឡើង ។

២៥. របាយការណ៍ដូចបានរៀបរាប់ខាងលើនេះ បង្ហាញថា ករណីទាំងឡាយដែលមានលក្ខណៈជារឿងនយោបាយកើតមានក្នុងទសវត្សកន្លងទៅនេះមិនមានការស៊ើបអង្កេត ឬធ្វើការចោទប្រកាន់អោយបានត្រឹមត្រូវឡើយ ។ ឃាតកម្មដែលមានរូបភាពជាការស៊ីឈ្នួលសំលាប់មនុស្សនៃប្រធានសហជីពកម្មករលោកជា វិជ្ជា និងលោករស់ សុវណ្ណារ៉េត នៅទីក្រុងភ្នំពេញ ក្នុងឆ្នាំ២០០៤ គឺជាករណីពីរ ក្នុងចំណោមករណីជាច្រើនទៀត ដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ ។ របាយការណ៍ធ្វើការសន្និដ្ឋានថា ជំហានផ្នែកច្បាប់និងនយោបាយដែលត្រូវអោយបង្កើតវប្បធម៌នៃការគោរពសិទ្ធិមនុស្ស និងធានាអោយមានការការពារសិទ្ធិផ្សេងៗតាមរយៈនីតិរដ្ឋ នៅមិនទាន់បានបង្កើតនៅឡើយ ។ ហើយបើទោះបីជាមានការខកខានក្នុងការនាំខ្លួនជនទាំងឡាយដែលទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌ និងការរំលោភសិទ្ធិមនុស្សទៅតុលាការ ដែលជារឿយៗគេតែងអះអាងថា មកពីការខ្វះធនធាន មន្ត្រីបំរើការនៅក្នុងស្ថាប័នអនុវត្តច្បាប់មានសមត្ថភាពទាប ហើយតុលាការមិនទាន់ដំណើរការបានល្អក៏ដោយ  ក៏ការខកខាននៃស្ថាប័នទាំងនេះក្នុងការពង្រឹងច្បាប់ អាចបង្ហាញឱ្យឃើញផងដែរពីការទទួលយកទំលាប់នៃនិទណ្ឌភាព និងការឃុបឃិតពីនគរបាល យោធានិងទីភ្នាក់ងារសន្តិសុខនានាដែរ ។ ការបន្តខុនភាពនៃច្បាប់និងស្ថាប័ននានា ក៏បានធ្វើឱ្យគ្មាននរណាការពារ ហើយបានបង្កើតឱ្យមានបរិយាកាសរំលោភបំពានសិទ្ធិ ។ របាយការណ៍សន្និដ្ឋានថា ការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមនៅពេលខាងមុខ "ដោយអង្គជំនុំជំរះ" វិសាមញ្ញនៃតុលាការកម្ពុជា មានសក្តានុពលដល់ការខិតខំធ្វើអោយមានការផ្លាស់ប្តូរពិតប្រាកដ ហើយរាល់ការខិតខំប្រឹងប្រែង ត្រូវតែចាត់ចែងឡើង ដើម្បីធានាថាសក្តានុពលនេះត្រូវសំរេចអោយបានដល់ការលើកកំពស់បទដ្ឋានជាទូទៅនៃដំណើរការនីតិវិធីដ៏ត្រឹមត្រូវ បង្កើតឱ្យមានការវាយតំលៃខ្ពស់ថែមទៀតអំពីនីតិរដ្ឋ និងសេចក្តីត្រូវការសំរាប់ការទទួលខុសត្រូវជាផ្លូវការ រវាងថ្នាក់ដឹកនាំនិងប្រជាពលរដ្ឋកម្ពុជា  ហើយត្រូវធានាថា ការជំនុំជំរះនេះ មិនត្រូវធ្វើដាច់ដោយឡែក ពីប្រព័ន្ធតុលាការកម្ពុជាដែលមានលក្ខណៈទូលាយជាងនោះឡើយ ។

២៦. របាយការណ៍នេះមានគោលបំណងជំរុញឱ្យមានការពិភាក្សាអោយបានទូលំទូលាយ និងក្នុងន័យស្ថាបនានៅក្នុងប្រទេសកម្ពុជា អំពីចរិត និងផលប៉ះពាល់នៃនិទណ្ឌភាព និងអំពីវិធានការទាំងឡាយដែលអាចធ្វើឡើងដើម្បីជំនះបញ្ហានេះ ។  លោកតំណាងពិសេសរំពឹងថា នឹងធ្វើការជាមួយរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ដើម្បីសំរេចកិច្ចការនេះ ។

### *ខ- ការអនុវត្តន៍ច្បាប់ចាំបាច់មួយចំនួន*

២៧- នៅក្នុងខែធ្នូ ឆ្នាំ២០០៤ រដ្ឋាភិបាលបានយល់ព្រមថា គណៈរដ្ឋមន្ត្រីនឹងអនុម័តសេចក្តីព្រាងច្បាប់ចំនួនប្រាំបីដែលមានសារៈសំខាន់ដល់ការពង្រឹងនីតិរដ្ឋ ហើយថានឹងបញ្ជូនច្បាប់ទាំងនេះទៅរដ្ឋសភា អោយបានមុនបំណាច់ឆ្នាំ ២០០៥ ។ ច្បាប់ទាំងនេះត្រូវតែស្របនឹងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា និងការអនុវត្តន៍ដ៏ប្រពៃជាអន្តរជាតិ ដូចមាន

ចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស ហើយច្បាប់ទាំងនេះនឹងត្រូវតាក់តែងឡើងដោយមានកិច្ចដំណើរការចូលរួមជាច្រើនគួរជាទីពេញចិត្ត ។ ច្បាប់ទាំងនេះរួមមាន ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់អង្គិនស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃតុលាការ ច្បាប់ស្តីពីវិសោធនកម្មនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញានិងច្បាប់ប្រឆាំងអំពើពុករលួយ ។ រដ្ឋាភិបាលមិនបានសំរេចគោលដៅទាំងនេះទេ ។ ដំណើរការនីតិវិធី នៃការតាក់តែងសេចក្តីព្រាងច្បាប់ទាំងនេះ បានបន្តជាប់គាំងដោយការអូសបន្លាយពេលវេលាច្រើនលើកច្រើនសារ ការខ្វះសេចក្តីណែនាំអំពីគោលនយោបាយនៃការធ្វើច្បាប់ ការខ្វះមន្ត្រីមានសមត្ថភាព ហើយចរិត និងវិសាលភាពនៃការពិនិត្យឡើងវិញដែលតំរូវដោយក្រុមប្រឹក្សាអ្នកច្បាប់ ។

២៨- ភាគច្រើននៃច្បាប់ទាំងនេះ មាននៅក្នុងរបៀបវារៈអស់មួយទសវត្សទៅហើយ ។ មានមធ្យោបាយជាច្រើនដែលអាចធ្វើឱ្យប្រសើរឡើងថែមទៀត ដល់កិច្ចដំណើរការព្រាងច្បាប់ ។ ឧទាហរណ៍ការណែនាំច្បាស់លាស់នៅកំរិតគោលនយោបាយនឹងជួយសំរួលដល់ការអនុម័តច្បាប់ ហើយការពិគ្រោះយោបល់ជាសាធារណៈដែលចេះតែកើនឡើងនិងមានអត្ថន័យ នឹងជួយកែលំអដល់គុណភាពនៃច្បាប់ ហើយក៏ជួយសំរួលដល់ការអនុវត្តន៍ និងការទទួលយកច្បាប់នេះជាសាធារណៈទៀតផង ។ វាមានសារៈសំខាន់ខ្លាំងណាស់ ដែលច្បាប់ទាំងនេះត្រូវតែស្របនឹងកាតព្វកិច្ចរបស់កម្ពុជាចំពោះសន្ធិសញ្ញាអន្តរជាតិ និងរដ្ឋធម្មនុញ្ញ ហើយត្រូវតែអនុម័តដោយគ្មានការពន្យាពេលមិនត្រឹមត្រូវនោះឡើយ ។

### *គ- ឯករាជ្យភាពនៃតុលាការ*

២៩- លោកតំណាងពិសេស បានទទួលបណ្តឹងជាច្រើនអំពីអង្គនីតិប្រតិបត្តិ ជ្រៀតជ្រែកចូលក្នុង កិច្ចការតុលាការ ហើយមានឧទាហរណ៍ជាច្រើននៃការជំនុំជំរះក្តី មិនបានគោរពតាមបទដ្ឋាន នៃកិច្ចដំណើរការនីតិវិធីដ៏ត្រឹមត្រូវ ។ ទាំងនេះគឺជាបញ្ហាធ្ងន់ធ្ងរដែលលោកមានបំណងពិនិត្យអោយបានដិតដល់ថែមទៀត នៅក្នុងដំណើរទស្សនកិច្ចលើកក្រោយរបស់លោក ។ នៅក្នុងបរិបទនេះ លោកក៏បានទទួលការរាយការណ៍ផងដែរអំពីបញ្ហានៃអំពើពុករលួយ នៅក្នុងស្ថាប័នតុលាការ និងវិធានការនានាដែលបានធ្វើឡើងតាម "គោលនយោបាយកណ្តាប់ដៃដែក" ដែលលោកនាយករដ្ឋមន្ត្រីបានប្រកាសកាលពីខែមីនា ឆ្នាំ២០០៥ ដើម្បីដោះស្រាយបញ្ហានេះ ។ លោកតំណាងពិសេសកោតសរសើរលោកនាយករដ្ឋមន្ត្រីដែលមានបំណងចាត់វិធានការយ៉ាងតឹងរឹងប្រឆាំងអំពើពុករលួយ ប៉ុន្តែលោកមានការព្រួយបារម្ភថា វិធានការដែលបានប្រើប្រាស់ គួរតែស្របទៅនឹងរដ្ឋធម្មនុញ្ញកម្ពុជា មិនត្រូវអនុញ្ញាតអោយនគរបាលប្រើប្រាស់ឥទ្ធិពលមិនសមស្រប ក្នុងករណីរឿងទាំងឡាយដែលបញ្ជូនមកតុលាការនោះឡើយ និងមិននាំឱ្យមានការបាត់បង់ឯករាជ្យនៃស្ថាប័នតុលាការទៀតផង ។ ដើម្បីសំរេចគោលដៅនេះនិងដើម្បីធានាការពារបូរណៈភាពនៃ

ស្ថាប័នតុលាការអោយបានកាន់តែទូលំទូលាយ គោលបំណងចម្បងត្រូវតែពង្រឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីធ្វើអោយក្រុមប្រឹក្សានេះ មានតំណាងច្រើនកាន់តែទូលាយ និងជៀសផុតពីគណៈបក្សនយោបាយ និងការជ្រៀតជ្រែកពីអំណាចនីតិប្រតិបត្តិ ។ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា ក៏ត្រូវការជាបន្ទាន់ផងដែរ ។ នៅពេលដែលគ្មានបញ្ញត្តិចែងលំអិតអំពីនីតិវិធីនៃការតែងតាំង និងលក្ខខណ្ឌការងាររបស់ចៅក្រម នីតិវិធីរដ្ឋបាលចាស់នៅតែបន្តអនុវត្ត ។ ដូច្នេះហើយ អំណាចនៅតែស្ថិតនៅក្នុងដៃក្រសួងយុត្តិធម៌ជាដដែល ដែលអំណាចនេះគួរជារបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមខ្លឹមសារនៃរដ្ឋធម្មនុញ្ញ ។ ក្រសួងយុត្តិធម៌នៅតែមានឥទ្ធិពលទៅលើតុលាការ ជាអាទិ៍ សន្តិសុខ និងការកាន់មុខតំណែងរបស់ចៅក្រម ។

## V. ដីធ្លី និងការគ្រប់គ្រងធនធានធម្មជាតិ

៣០- នៅក្នុងបេសកកម្មរបស់លោក លោកតំណាងពិសេសបានដឹងអំពីការលំបាកជាច្រើន ដែលសហគមន៍ជនជាតិដើមភាគតិច និងប្រជាពលរដ្ឋជនបទ កំពុងជួបប្រទះក្នុងការទ្រទ្រង់ជីវភាពរបស់ខ្លួន ដោយសារតែលទ្ធផលនៃការបាត់បង់ដីធ្លី និងសិទ្ធិប្រើប្រាស់ធនធានធម្មជាតិ ។ លោកចូលរួមយោបល់យ៉ាងពេញទំហឹង ក៏ដូចជាលោកនាយករដ្ឋមន្ត្រីបានថ្លែងដែរថា កម្ពុជាត្រូវធ្វើដូចម្តេចដើម្បីប្រើប្រាស់ និងបែងចែកធនធានធម្មជាតិរបស់ខ្លួន ហើយដើម្បីផលប្រយោជន៍របស់នរណា គឺជាបញ្ហាសំខាន់បំផុតមួយ ដែលប្រទេសកម្ពុជាកំពុងតែប្រឈមមុខនាពេលបច្ចុប្បន្ននេះ ។ ការប្រើប្រាស់ និងការបំពានលើដែននេសាទ ព្រៃឈើ ដីធ្លី និងធនធានដទៃទៀត បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិមនុស្ស ជីវភាពរស់នៅ និងវប្បធម៌របស់ប្រជាពលរដ្ឋតាមជនបទនៃប្រទេសកម្ពុជា រួមទាំងជនជាតិដើមភាគតិច ដែលងាយរងគ្រោះជាពិសេស ។ លោកតំណាងពិសេសនឹងបន្ថែមលើរបាយការណ៍ និងអនុសាសន៍របស់លោកតំណាងពិសេសមុនៗ ក្នុងការជួយដល់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុងការដោះស្រាយបញ្ហាទាំងនេះ ។ បញ្ហាទាំងនេះមានលក្ខណៈធំធេង ហើយត្រូវការការយកចិត្តទុកដាក់ជាខ្លាំងនៅគ្រប់ស្រទាប់ជាន់ថ្នាក់ ដោយជនទាំងឡាយដែលពាក់ព័ន្ធ ។

៣១- លោកតំណាងពិសេសសូមស្វាគមន៍ចំពោះការអនុម័តអនុក្រឹត្យផ្សេងៗនៃច្បាប់ភូមិបាលឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងដីរដ្ឋ និង ការផ្តល់និងការកាត់បន្ថយសម្បទានដីគោលដៅសេដ្ឋកិច្ច ទោះបីជាលោកមិនមានឱកាសសិក្សាអោយបានលំអិតអំពីបញ្ហាទាំងនេះក៏ដោយ ។ លោកកត់សំគាល់ថា រដ្ឋាភិបាលមិនទាន់បានចាត់វិធានការណាមួយពាក់ព័ន្ធនឹងកិច្ចដំណើរការចេញប័ណ្ណកាន់កាប់ដីធ្លីអោយសហគមន៍ជនជាតិដើមភាគតិច ដូចមានចែងនៅក្នុងច្បាប់ភូមិបាលនៅឡើយទេ ។ លោកចូលរួមក្នុងការព្រួយបារម្ភយ៉ាងពេញទំហឹង អំពីអនាគតរបស់ជនជាតិដើមភាគតិចកម្ពុជាដែលកំពុងតែបាត់បង់ដីធ្លីរបស់ខ្លួនយ៉ាងឆាប់រហ័ស ទៅឱ្យបុគ្គល ឬក្រុមហ៊ុនឯកជន ហើយលោកយល់ស្រប

ថា ការផ្អាកជាបណ្តោះអាសន្នគួរតែត្រូវបានប្រកាសចំពោះការផ្តល់ឬការលក់ដីដែលសមស្របសំរាប់ការចេញប័ណ្ណកាន់កាប់ដីធ្លីអោយជនជាតិដើមភាគតិច រហូតដល់មាននីតិវិធានការផ្សេងៗដើម្បីធានាដល់ការចេញប័ណ្ណកាន់កាប់ដីធ្លីឱ្យជនជាតិដើមភាគតិច ។

៣២- ដំបូងបំផុត វាមានសារសំខាន់ខ្លាំងណាស់ ចំពោះប្រជាពលរដ្ឋកម្ពុជា ត្រូវដឹងអំពីថាតើដី និងធនធានធម្មជាតិរបស់រដ្ឋចំនួនប៉ុន្មាន ត្រូវបានប្រគល់ទៅឱ្យក្រុមហ៊ុនឯកជននានា ឬទៅឱ្យយោធាកម្ពុជាគ្រប់គ្រង និងអភិវឌ្ឍន៍ ហើយក្នុងគោលបំណងអ្វីខ្លះ ។ នៅក្នុងសម័យប្រជុំក្រុមពិគ្រោះយោបល់សំរាប់កម្ពុជា កាលពីខែធ្នូ ឆ្នាំ២០០៤ រដ្ឋាភិបាល បានសន្យាថា នឹងធ្វើការផ្សព្វផ្សាយជាបន្ទាន់នូវព័ត៌មាននេះដល់សាធារណៈជនបានដឹង ។ ព័ត៌មានមួយចំនួនស្តីពីដីសម្បទានគោលដៅសេដ្ឋកិច្ច គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់ឱ្យជាយថាហេតុកាលពីខែធ្នូ ក៏ប៉ុន្តែឯកសារទាំងនេះមិនទាន់បានបកប្រែ និង ធ្វើវិភាគនៅឡើយ ។ ប្រសិនបើមិនដូច្នេះទេ គ្មានព័ត៌មានណាមួយត្រូវបានផ្តល់អោយនោះទេ ។

៣៣- សភាពការណ៍នៅឃុំទុំរីងក្នុងខេត្តកំពង់ធំ បង្ហាញឱ្យឃើញច្បាស់អំពីភាពងាយរងគ្រោះនៃសហគមន៍ជនបទដែលរស់នៅក្នុងតំបន់ដាច់ស្រយាល ហើយសភាពការណ៍ធ្ងន់ធ្ងរមួយចំនួនអាចកើតមានបាន ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយ ឃុំទុំរីងបាននឹងកំពុងប្រឈមមុខនឹងបញ្ហាសន្តិសុខ ដែលភាគច្រើនបណ្តាលមកពីកំលាំងសន្តិសុខដែលក្រុមហ៊ុនឯកជននានាបានជួលឱ្យយាមល្បាតនៅតំបន់នោះ ហើយមានក្រុមហ៊ុនខ្លះ ជាប់ពាក់ព័ន្ធក្នុងការកាប់ឈើខុសច្បាប់ទៀតផង ។ ប្រជាជនមូលដ្ឋាន បានប្រឈមមុខជារឿយៗជាមួយកំលាំងសន្តិសុខក្រុមហ៊ុន ជាពិសេសនៅពេលដែលពួកគេព្យាយាមបញ្ឈប់ការកាប់ឈើច្បោះខុសច្បាប់ដែលប្រជាជនមូលដ្ឋានពឹងផ្អែកលើការចោះយកជ័រជារបរចិញ្ចឹមជីវិត ។ ពួកគេបានបង្កើតជាសហគមន៍ព្រៃឈើ ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។ កងកំលាំងសន្តិសុខដែលខ្លាំង និងមានឈ្មោះអាក្រក់ជាងគេ គឺកងសន្តិសុខដែលនៅក្រោមបញ្ជារបស់លោកកុក ហៀង ដែលត្រូវជាប្អូនប្រុសរបស់ប្រធានក្រុមហ៊ុនសេង គាង ។ បើតាមប្រភពព័ត៌មានគួរឱ្យទុកចិត្តបាន ក្រុមនេះមានជាប់ពាក់ព័ន្ធនឹងការស៊ីសំណូក ការបង្ខិតបង្ខំ ការបៀតបៀន ការគំរាមកំហែង និងហេតុការណ៍បាញ់បោះជាក់ស្តែង ក្នុងនោះក៏មានការបាញ់សំលាប់សកម្មជនសហគមន៍ព្រៃឈើ ២នាក់ កាលពីខែកក្កដា ឆ្នាំ២០០៥ ។ អាជ្ញាធរខេត្តនិយាយថា ខេត្តក៏មានការព្រួយបារម្ភក្នុងរឿងនេះដែរ ប៉ុន្តែត្រូវការជំនួយពីអាជ្ញាធរជាតិដើម្បីដកអាវុធនិងធ្វើការស៊ើបអង្កេតលោកកុក ហៀង និងបក្សពួក ហើយដើម្បីធ្វើឱ្យសភាពការណ៍សន្តិសុខនៅឃុំទុំរីងបានល្អប្រសើរឡើងថែមទៀត ។ ក្រសួងមហាផ្ទៃបានដឹងអំពីបញ្ហានេះហើយ ហើយលោកតំណាងពិសេសសង្ឃឹមថា ការធ្វើអន្តរាគមន៍របស់ក្រសួងមហាផ្ទៃ នឹងមានប្រសិទ្ធិភាព ។ ដូចដែលបានផ្តល់អនុសាសន៍រួចមកហើយ បទល្មើសព្រហ្មទណ្ឌដែលបានប្រព្រឹត្ត

ដោយកងកំលាំងសន្តិសុខក្រុមហ៊ុន កងសេនាជនលើដីសម្បទាន និងនៅចំការកៅស៊ូត្រូវតែធ្វើការស៊ើបអង្កេត និងធ្វើការចោទប្រកាន់ ហើយកងកំលាំងទាំងនេះត្រូវតែបានដកអាវុធ ធ្វើយ៉ាងណាអោយស្របតាមច្បាប់ជាធរមាន ។

៣៤- នៅក្នុងបេសកកម្មរបស់លោក លោកតំណាងពិសេសបានធ្វើទស្សនកិច្ចទៅកាន់ខេត្តកំពង់ស្ពឺ ហើយលោកមានឱកាសបានជួបជាមួយតំណាងសហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលនានា ។ ក្នុងចំណោមដីសម្បទានគោលដៅសេដ្ឋកិច្ចចំនួន៤៩កន្លែងដែលបានចុះបញ្ជីនៅក្រសួងកសិកម្មក្នុងឆ្នាំ២០០៥ មានដីសម្បទានចំនួន១១កន្លែងស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ ។ សម្បទានសំរាប់គោលដៅផ្សេងទៀតមិនបានចែងនៅក្នុងបញ្ជី មានទីតាំងនៅតំបន់ដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ។

៣៥- ដីសម្បទានមួយកន្លែង គឺជាដីសម្បទានគោលដៅទេសចរណ៍បរិស្ថាន ដែលរដ្ឋាភិបាលបានផ្តល់ឱ្យក្រុមហ៊ុនចិនមួយឈ្មោះក្រុមហ៊ុន New Cosmos Development (Cambodia) Co., Ltd, នៅក្នុងឆ្នាំ២០០៤ ។ ក្រុមហ៊ុននេះបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ដែលមានដើមទុនសរុប៥.០០០ ដុល្លាអាមេរិក នៅក្នុងខែកុម្ភៈឆ្នាំ២០០៣ ។ មួយខែក្រោយមក ក្រុមហ៊ុននេះបានស្នើសុំដីទំហំ ៩០០ហិកតា សំរាប់រយៈពេល៩៩ឆ្នាំ នៅក្នុងតំបន់មួយដែលមានទឹកពុះធម្មជាតិ នៅក្នុងតំបន់ដែនជំរកសត្វព្រៃភ្នំឱរ៉ាល់ ដើម្បីអភិវឌ្ឍន៍ជារមណីយដ្ឋាន និងកន្លែងកំសាន្ត រួមមានភូមិទេសចរណ៍ទឹកពុះធម្មជាតិ មជ្ឈមណ្ឌលសន្និសិទអន្តរជាតិ ភូមិវប្បធម៌បូរាណ សួនកំសាន្ត តំបន់និវេសនដ្ឋានប្រណិត១ និងទីលានវាយកូនគោល ។ រដ្ឋាភិបាលបានឯកភាពជាគោលការណ៍ ហើយនៅក្នុងខែឧសភា ឆ្នាំ២០០៤ ទើបរដ្ឋាភិបាលបានយល់ព្រមលើសំណើសុំរបស់ក្រុមហ៊ុន ក្នុងការពង្រីកផ្ទៃដី រហូតដល់១៩០០ហិកតា ។ ក្រុមហ៊ុនបានចាប់ផ្តើមធ្វើសកម្មភាពនៅពាក់កណ្តាលឆ្នាំ២០០៤ ។ គ្មានការវាយតំលៃពីបច្ច័យប៉ះពាល់ខាងសង្គមនិងបរិស្ថានត្រូវបានធ្វើឡើយ ។

៣៦- ជនជាតិដើមភាគតិចសួយ បានរស់នៅក្នុងតំបន់ភ្នំឱរ៉ាល់ ជាច្រើនជំនាន់មកហើយ ។ ក្រោយរបបគ្រប់គ្រងខ្មែរក្រហម ពួកគេបានប្តូរពីការដាំដុះតាមបែបពនេចរ ទៅជាការដាំដុះមានលក្ខណៈជាអចិន្ត្រៃយ៍វិញ ។ សហគមន៍នេះមានប្រជាពលរដ្ឋប្រមាណជា ២០០គ្រួសារ ដែលមានប្រជាជនសរុបប្រហែលជា៩០០នាក់ ។ ទឹកពុះធម្មជាតិ និងព្រៃឈើដែលស្ថិតនៅជុំជិតទីនោះ មានអត្ថន័យធំធេងណាស់ខាងផ្លូវចិត្តចំពោះជនជាតិដើមភាគតិចសួយនេះ ។ ពួកគេរស់នៅដោយពឹងផ្អែកផងដែរលើព្រៃឈើ ជំរកសត្វព្រៃ រួមមានសត្វក្តាន់ ខ្លាឃ្មុំ និងសត្វបក្សាបក្សីជាង៦០ ជំពូកទៀត ។ ដោយយល់ឃើញថាទឹកពុះធម្មជាតិ ព្រៃឈើ ស្ទឹង និងវប្បធម៌ជនជាតិសួយមានសក្តានុពលខ្លាំងដល់ការអភិវឌ្ឍន៍ជាតំបន់កសិ-ទេសចរណ៍ អង្គការ Lutheran World Federation និងអង្គការ Flora and Fauna International បានធ្វើការជាមួយជនជាតិដើមភាគតិចសួយ និងអាជ្ញាធរមូលដ្ឋានអស់រយៈពេលជាច្រើនឆ្នាំមកហើយ

ដើម្បីជួយពួកគេអោយយកតំបន់ទឹកពុះធម្មជាតិនេះ មកស្ថិតក្រោមការគ្រប់គ្រងនៃគំរោងរបស់សហគមន៍ផ្នែកលើទេសចរណ៍បរិស្ថាន ។ នៅពេលដែលជនជាតិស្ទួយបានដឹងអំពីគំរោងរបស់ក្រុមហ៊ុនNew Cosmos ពួកគេ និងអង្គការក្រៅរដ្ឋាភិបាលបានធ្វើការអំពាវនាវដល់រដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ អោយបញ្ឈប់គំរោងនេះ ប៉ុន្តែការអំពាវនាវនោះគ្រាន់តែជាការឥតប្រយោជន៍ប៉ុណ្ណោះ ។

៣៧- ជាយកថាហេតុ រដ្ឋាភិបាលបានឯកភាពចំពោះការវាយតំលៃពីបច្ច័យប៉ះពាល់បរិស្ថាន ។ យោងតាមរបាយការណ៍ដំបូង ចុះខែមិថុនា ឆ្នាំ២០០៥ ដែលរៀបចំដោយក្រុមហ៊ុន Strategic Consultancy Servives Co. Ltd, បច្ច័យប៉ះពាល់នៃគំរោងនឹងមានតិចតួចនិងអាចគ្រប់គ្រងបាន ហើយនឹងមិនមានផលប៉ះពាល់កាន់តែច្រើនឡើង និងជាដំកំភួនដល់បរិស្ថានឡើយ ។ របាយការណ៍បានរកឃើញថា ការវិនិយោទុនតាមគំរោងបែបនេះ បានបង្ហាញឱកាសតែមួយគ្មានពីរសំរាប់ប្រទេសកម្ពុជា ក្នុងការបង្វែរសម្បត្តិធម្មជាតិឱ្យទៅជាការធ្វើចរាចររូបិយវត្ថុ តាមរបៀបមួយដែលអាចមានចិរភាព ដោយផ្តល់ផលប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ដល់ប្រទេសកម្ពុជា ។ ដើម្បីបំពេញសេចក្តីត្រូវការរបស់ជនជាតិដើមភាគតិចស្ទួយ និងធ្វើឱ្យពួកគេអាចប្រតិបត្តិជំនឿសាសនារបស់ពួកគេបាន ក្រុមហ៊ុនបាននិយាយថា ក្រុមហ៊ុននឹងអនុញ្ញាតពួកគេឱ្យមានសិទ្ធិប្រើទឹកក្តៅពុះធម្មជាតិនេះ និងតំបន់នៅជុំជិតទីនោះ ឬក៏អាចចេញចំណាយលើការផ្លាស់ប្តូរទីលំនៅរបស់ពួកគេទៅកាន់កន្លែងផ្សេង និងសាងសង់ទីកន្លែងសក្ការៈតូចមួយសំរាប់ដាក់អ្នកដូនរបស់គេ គឺយាយតេ និងសំរាប់រៀបចំពិធីបុណ្យសាសនាផ្សេងៗ ។ របាយការណ៍បានបញ្ជាក់ថាប្រជាពលរដ្ឋមូលដ្ឋានបានគាំទ្រគំរោងនេះ ហើយចង់ឱ្យមានការអភិវឌ្ឍន៍ឆាប់ៗដើម្បីពួកគេអាចមានការងារធ្វើ ។ ទោះបីយ៉ាងដូច្នេះក៏ដោយ ក្នុងការធ្វើការវាយតំលៃនេះ គេឃើញមានអ្នកស្រុកតែពីរបីគ្រួសារប៉ុណ្ណោះ ក្រៅពីនេះគឺសុទ្ធតែអ្នកមកតាំងទីលំនៅថ្មីទាំងអស់ ដែលបានរស់នៅជិតកន្លែងទឹកពុះធម្មជាតិនេះបានទទួលការពិគ្រោះយោបល់ ។

៣៨- ជនជាតិដើមភាគតិចស្ទួយ បានធ្វើការតវ៉ាយ៉ាងខ្លាំងចំពោះការវាយតំលៃនេះ ហើយនិយាយថា មិនដែលឃើញមាននរណាមកពិគ្រោះយោបល់ជាមួយពួកគេអំពីបញ្ហានេះឡើយ ។ ពួកគេភ័យខ្លាចពីការវិនាសសាបសូន្យវប្បធម៌ និងរបៀបរបបរស់នៅរបស់គេ ។ អង្គការក្រៅរដ្ឋាភិបាល និងអ្នកដទៃទៀតក៏បានចែករំលែកការព្រួយបារម្ភនេះដែរ ។ សហគមន៍ និងអ្នកតំណាងរបស់គេកំពុងស្ថិតក្រោមការគំរាមកំហែងនិងការគាបសង្កត់ជាបន្តបន្ទាប់និងកាន់តែខ្លាំងឡើងៗ ។ សមាជិកក្រុមប្រឹក្សាឃុំ នគរបាល និងមន្ត្រីមួយចំនួនរបស់ខេត្ត និងស្រុក បានប្រាប់ពួកគេអោយទទួលយកសំណើររបស់ក្រុមហ៊ុន និងឈប់ធ្វើការតវ៉ាតទៅទៀត បើពុំនោះទេពួកគេនឹងត្រូវចាប់ខ្លួន ពីព្រោះរដ្ឋាភិបាលបានផ្តល់សម្បទានឱ្យទៅក្រុមហ៊ុននោះរួចហើយ ។

៣៩- លោកតំណាងពិសេសក៏បានទទួលការរាយការណ៍ អំពីជំលោះដីធ្លីជាច្រើនទៀតដែលកំពុងតែស្ថិតក្នុងវិវាទនៅក្នុងខេត្តមួយ ដែលមានប្រជាពលរដ្ឋក្រីក្រជាច្រើនគ្រួសារកំពុងធ្វើការតវ៉ាយ៉ាងខ្លាំងក្លាប្រឆាំងនឹងមន្ត្រីយោធា ឬមន្ត្រីជាន់ខ្ពស់ ។ គេក៏បានរាយការណ៍ប្រាប់គាត់ដែរថានៅពេលដែលរឿងក្តីទាំងនេះប្តឹងទៅតុលាការ ប្រជាពលរដ្ឋតែងតែចាញ់ក្តីជានិច្ច ។ តាមការគូសបញ្ជាក់នេះមានវិវាទមួយទាក់ទងនឹងជំលោះរវាងប្រជាពលរដ្ឋក្រីក្រមួយក្រុមប្រមាណជា២០គ្រួសារ និងយោធភូមិភាគទី៣ ដោយយោធាទាមទារយកដីទំនាស់នេះ រីឯប្រជាពលរដ្ឋនិយាយថាពួកគេបានកាន់កាប់ដីនេះតាំងពីឆ្នាំ១៩៩៧ នៅពេលយោធាបានរើចេញ ។ យោធាក៏បានចោទប្រកាន់អ្នកតាំងទីលំនៅថ្មីនៅតាមបណ្តោយផ្លូវលេខ៤២ ពីការបង្កអោយមានវិវាទដីធ្លីដោយការទន្ទ្រានចាប់យកដោយខុសច្បាប់លើដីរដ្ឋ ។ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ជំលោះហឹង្សាមួយបានផ្ទុះឡើង នៅពេលដែលនគរបាល និងយោធាបានមកគំរាមដុតផ្ទះរបស់អ្នកតាំងទីលំនៅថ្មី និងរបស់ប្រជាពលរដ្ឋ២០គ្រួសារ ប្រសិនបើពួកគេមិនរុះរើចេញទេ ។ នៅក្នុងហេតុការណ៍នេះ គ្មាននរណាម្នាក់រងរបួសទេ ប៉ុន្តែមនុស្សប្រាំបីនាក់ត្រូវបានចាប់ខ្លួនហើយនៅពេលកំពុងធ្វើរបាយការណ៍នេះ ជនទាំងនោះត្រូវគេឃុំខ្លួននៅពន្ធនាគារខេត្តពីបទ "ការរំលោភកាន់កាប់អចលនទ្រព្យ និងការប្រើអំពើហឹង្សា" ។

៤០- មិនយូរប៉ុន្មានបន្ទាប់ពីហេតុការណ៍នេះភ្លាម មេបញ្ជាការយោធភូមិភាគ៣ បានរៀបចំរបាយការណ៍មួយដាក់ជូនលោកឧត្តមសេនីយ៍ មាស សុភា អគ្គមេបញ្ជាការកងទ័ពជើងគោកនៃក្រសួងការពារជាតិ ។ របាយការណ៍នេះបានភ្ជាប់វិវាទនេះទៅនឹងវគ្គបណ្តុះបណ្តាលមួយស្តីពីការតស៊ូមតិ ដែលរៀបចំកាលពីថ្ងៃទី៧ ខែវិច្ឆិកា ដោយអង្គការ Lutheran World Federation ដែលអង្គការនេះមានទំនាក់ទំនងសហប្រតិបត្តិការជិតស្និទ្ធជាយូរមកហើយជាមួយអាជ្ញាធរមូលដ្ឋាន និងសហគមន៍ ក្នុងការខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីជំរុញអោយមានការអភិវឌ្ឍន៍ប្រកបដោយចិរភាព និងការកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ ហើយដើម្បីដោះស្រាយជំលោះដែលកើតឡើងដោយសន្តិវិធី ។ របាយការណ៍បានស្តីបន្ទោសវគ្គបណ្តុះបណ្តាលអំពីការតស៊ូមតិនេះ ថានាំឱ្យមានអំពើហឹង្សា ហើយបានរអ៊ូរទាំថា ជាទូទៅ អង្គការក្រៅរដ្ឋាភិបាលកំពុងតែញុះញង់អ្នកស្រុកឱ្យធ្វើការប្រឆាំងនឹងអាជ្ញាធរ ។

៤១- របាយការណ៍ដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស របស់អ្នករាយការណ៍ពិសេសខាងសិទ្ធិមានលំនៅដ្ឋានសមរម្យដែលជាផ្នែកមួយនៃសិទ្ធិមានក៏រិតជីវភាពសមរម្យ និងសិទ្ធិទទួលបានពីភាពគ្មានការរើសអើងនៅក្នុងបរិបទនេះ ផ្តល់ព័ត៌មានបន្ថែមទៀតអំពីជំលោះដីធ្លី និងផលប៉ះពាល់ខាងលំនៅដ្ឋាន ជាពិសេសនៅតំបន់ទីក្រុង (សូមមើលរបាយការណ៍លេខ E/CN.4/2006/41/Add.3) ។ លោកតំណាងពិសេសសង្ឃឹមថា រដ្ឋាភិបាល និងសហគមន៍អន្តរជាតិនឹងធ្វើការពិចារណាយ៉ាងល្អិតល្អន់លើរបាយការណ៍របស់លោក ហើយលោកសង្ឃឹមថា អនុសាសន៍របស់លោកនឹងត្រូវបានទទួលយក ។

## VI- **ការបង្កើតបរិយាកាស ដែលនាំឱ្យមានសកម្មភាពនយោបាយស្របច្បាប់**

៤២- នៅក្នុងសេចក្តីសំរេចលេខ២០០៥/៧៧ គណៈកម្មការបានគូសបញ្ជាក់ពីសារសំខាន់នៃការបន្តបង្កើតបរិយា-កាសដែលនាំឱ្យមានសកម្មភាពនយោបាយស្របច្បាប់ ក៏ដូចជាការគាំទ្រដល់តួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល ដើម្បីពង្រឹងការអភិវឌ្ឍន៍លិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។ វិសាលភាព ដែលប្រជាពលរដ្ឋកម្ពុជាអាចអនុវត្តសេរីភាពរបស់ខ្លួនក្នុងការសំដែងមតិ ក្នុងការបង្កើតសមាគម និងក្នុងការប្រជុំ តាមមធ្យោបាយមួយដ៏មានប្រសិទ្ធភាព និងមានអត្ថន័យ គឺជាគន្លឹះសំរាប់បង្កើតអោយមានបរិយាកាសបែបនេះ ។ សេរីភាពជាមូលដ្ឋានទាំងនេះ បង្កើតបានជាគ្រឹះដ៏សំខាន់សំរាប់សង្គមប្រជាធិបតេយ្យ ហើយវាក៏ជាលក្ខខណ្ឌចម្បងមួយ ក្នុងចំណោមលក្ខខណ្ឌដទៃទៀត សំរាប់ការរីកចំរើនរបស់សង្គមប្រជាធិបតេយ្យ ។ ទោះជាយ៉ាងណាក៏ដោយ សន្ទុះកថានយោបាយស្របច្បាប់ និងការជជែកពិភាក្សាជាសាធារណៈ កាន់តែមានភាពស្រួចស្រាលឡើង ជាពិសេសទោះជាតុលាការក៏ដោយ ។

### *ក- ការព្យួរអភ័យឯកសិទ្ធិសមាជិករដ្ឋសភា*

៤៣- កាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៥ រដ្ឋសភាបានព្យួរអភ័យឯកសិទ្ធិរបស់លោកសម រង្ស៊ី និងសមាជិកគណៈបក្សពីររូបទៀតគឺលោកជា ប៉ូចនិងលោកជាម ច័ន្ទនី ។ រដ្ឋសភាបានធ្វើការបោះឆ្នោតដោយមិនបានជូនដំណឹងជាមុន ធ្វើឡើងនៅក្នុងសម័យប្រជុំបិទជិតដោយធ្វើការលើកដៃ ហើយកំណត់ហេតុប្រជុំមិនត្រូវបានផ្សព្វផ្សាយឡើយ ។

៤៤- ខណៈដែលការព្យួរអភ័យឯកសិទ្ធិលោកសម រង្ស៊ី និងលោកជា ប៉ូច ទាក់ទងពីបទបរិហាកេរ្តិ៍ ការចាប់ខ្លួនលោកជាម ច័ន្ទនី ជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់ ដែលលោកនាយករដ្ឋមន្ត្រី បានថ្លែងកាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៤ គឺបីថ្ងៃបន្ទាប់ពីការបង្កើតរដ្ឋាភិបាលចំរុះនៅថ្ងៃទី១៥ ខែកក្កដា ថាលោកជាម ច័ន្ទនីបានរៀបចំបង្កើតកងទ័ពជាសំងាត់ ។ លោកជាម ច័ន្ទនី ត្រូវបានចាប់ខ្លួននៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០០៥ ហើយត្រូវបានចោទប្រកាន់ពីបទ "ក្រុមជនប្រដាប់អាវុធ" និង "អំពើឆបោក" តាមមាត្រា៣៦ និងមាត្រា៤៥នៃច្បាប់អ៊ុនតាក់ ។ (គួរកត់សំគាល់ថា ច្បាប់អ៊ុនតាក់ត្រូវបានរៀបរៀងដោយអ៊ុនតាក់ ហើយអនុម័តដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់) ។ ដោយផ្ទុយទៅនឹងច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលអនុវត្តនៅក្នុងប្រទេសកម្ពុជា លោកជាម ច័ន្ទនីត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំងយោធា ហើយជំនុំជំរះដោយតុលាការយោធា ទោះបីគាត់ជាជនស៊ីវិលក៏ដោយ ។ នៅថ្ងៃទី៨ ខែសីហា គាត់បានត្រូវតុលាការរកឃើញថាមានពិរុទ្ធភាព ហើយបានត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលប្រាំពីរឆ្នាំ ។ តុលាការយោធាមិនបានគោរពសិទ្ធិស្របច្បាប់ជាមូលដ្ឋានរបស់គាត់ឡើយ ។ ចៅក្រមបានរារាំងមេធាវីចុងចោទមិនឱ្យហៅសាក្សីមកឆ្លើយបំភ្លឺ ហើយបានរារាំងមេធាវីមិនអោយសួរសាក្សីដាក់បន្ទុកឡើយ ។ គ្មានភស្តុតាងត្រូវបានបង្ហាញអោយឃើញជាក់ស្តែងពីការស៊ីសង្វាក់គ្នាជាមួយការចោទប្រកាន់ដែលថាលោកជាម ច័ន្ទនី បានរៀបចំអាវុធឬរៀប

ចំឌុបាយកលសំងាត់ក្នុងគោលបំណងផ្តួលរំលំរដ្ឋាភិបាលនោះទេ ។ មួយថ្ងៃមុនផុតរយៈពេលពីរខែនៃការប្តឹងឧទ្ធរណ៍ លោកជាម ច័ន្ទនីបានប្រាប់មេធាវីរបស់លោក កុំឱ្យប្តឹងឧទ្ធរណ៍ ហើយសាលក្រមក៏បានចូលជាស្ថាពរកាលពីថ្ងៃទី៩ ខែតុលា ។ បច្ចុប្បន្នលោកជាម ច័ន្ទនី កំពុងតែបំរើទោសនៅក្នុងពន្ធនាគារយោធា ។ នៅក្នុងអំឡុងពេលបំពេញបេសកកម្មរបស់លោក លោកតំណាងពិសេសអាចចូលសួរសុខទុក្ខលោកជាម ច័ន្ទនី ។ លោកតំណាងពិសេសបានចូលរួមជាមួយអ្នកដទៃទៀត ក្នុងការអំពាវនាវសុំឱ្យដោះលែងលោកជាម ច័ន្ទនី ។

៤៥- កាលពីថ្ងៃទី២២ ខែធ្នូ លោកសម រង្ស៊ី បានត្រូវតុលាការក្រុងភ្នំពេញបើកសវនាការកំបាំងមុខពីបទបរិហាកេរ្តិ៍ព្រហ្មទណ្ឌ លើពីរករណី ហើយបានត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល១៨ ខែ ។ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ លោកតំណាងពិសេសបានចេញសេចក្តីថ្លែងការណ៍ជាសាធារណៈមួយ សំដែងពីការព្រួយបារម្ភយ៉ាងខ្លាំង និងពីជំនឿយ៉ាងមុតមាំរបស់លោកថា ការខ្វែងមតិយោបល់គ្នា គួរតែត្រូវតទល់គ្នាតាមរយៈការជជែកវែកញែកជាសាធារណៈ មិនគួរធ្វើតាមរយៈបណ្តឹងព្រហ្មទណ្ឌឡើយ ។ តាមយោបល់របស់លោក សវនាការកំបាំងមុខមិនស្របទៅនឹងការធានានៃនីតិវិធីដ៏ត្រឹមត្រូវដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយឡើយ ។

## ខ- ការបរិហារកេរ្តិ៍

៤៦- ការប្រើច្បាប់ស្តីពីការបរិហាកេរ្តិ៍តាមមាត្រា៦៣នៃច្បាប់អ៊ុនតាក់ កាន់តែច្រើនឡើង១ ដើម្បីដោះស្រាយវិវាទ ឬជិវាទផ្សេង១ដែលជាពិសេសមានចរិកនយោបាយ គឺជាសញ្ញា និងជាមូលហេតុនៃការបំបិទគំលាតនយោបាយ ។ លោកតំណាងពិសេសមានការព្រួយបារម្ភដូចគ្នា ចំពោះការប្រើប្រាស់បញ្ញត្តិស្តីពីការញុះញង់ និងការផ្សាយព័ត៌មានមិនពិតនៃច្បាប់អ៊ុនតាក់ និងអំពីភាពមិនប្រក្រតីនានា ដែលបានចង្អុលពីចរិតលក្ខណៈក្នុងការទទួលរឿងក្តីថ្មី១នេះរបស់តុលាការ ។ លោកជឿជាក់ថា និន្នាការនេះគឺជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សេរីភាពនៃការសំដែងមតិ និងនយោបាយពហុបក្សនៅក្នុងប្រទេសកម្ពុជា ។

៤៧- តាមមាត្រា៦៣នៃច្បាប់អ៊ុនតាក់ ការបរិហាកេរ្តិ៍ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារជាអតិបរមារយៈពេលមួយឆ្នាំ រីឯការញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមមិនបានសំរេចតាមមាត្រា៦០ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ប្រាំឆ្នាំ ។ តាមមាត្រា៦២ ការផ្សាយព័ត៌មានមិនពិតត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់បីឆ្នាំ ។

៤៨- ច្បាប់អ៊ុនតាក់បានត្រូវរៀបរៀងដោយអ៊ុនតាក់ ហើយអនុម័តដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ មានបំណងដាក់ឱ្យប្រើប្រាស់ជាបណ្តោះអាសន្នតែប៉ុណ្ណោះ ។ ច្បាប់នេះត្រូវបានអនុម័ត ក្រោមកាលៈទេសៈពិសេសបំផុតដែល

លែងឆ្លុះបញ្ចាំងពីសភាពការណ៍កម្ពុជាបច្ចុប្បន្ននេះទៅហើយ ។ ចរិតបណ្ដោះអាសន្នរបស់ច្បាប់នេះ ត្រូវបានបញ្ជាក់យ៉ាងច្បាស់មិនត្រឹមតែដោយសេចក្ដីយោងនៅក្នុងបុព្វកថា ចំពោះសភាពការណ៍ដែលកើតមាននៅពេលកំពុងព្រាងច្បាប់នេះប៉ុណ្ណោះទេ ប៉ុន្ដែថែមទាំងមាននៅក្នុងសេចក្ដីយោងជាច្រើនទៀតនៅក្នុងអត្ថបទរបស់អ៊ុនតាក់ ដែលលែងមានអត្ថិភាពនៅក្នុងឆ្នាំ១៩៩៣ទៀតផង ។ ច្បាប់នេះត្រូវបានអនុម័ត មុនពេលដែលប្រទេសកម្ពុជាបានអនុម័តរដ្ឋធម្មនុញ្ញរបស់ខ្លួន និងមុនពេលចូលជាសមាជិកនៃសន្ធិសញ្ញាអន្តរជាតិសំខាន់ៗ ស្ដីពីសិទ្ធិមនុស្ស ជាពិសេស កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។

៤៩- ការផ្ដន្ទាទោសចំពោះការនិយាយស្ដី តាមរយៈច្បាប់ព្រហ្មទណ្ឌមានប្រវត្តិយូរលង់មកហើយ ។ នៅក្នុងប្រទេសជាច្រើន ប្រវត្តិសាស្ត្របែបនេះមានជាប់ទាក់ទងយ៉ាងជិតស្និតទៅនឹងការនាំបំប៉ះបំបោរ ហើយមានការព្រួយបារម្ភពីការរក្សាសន្តិភាព ជាជាងការការពារកិត្តិស័ព្ទរបស់ប្រទេស ។ បើតាមគំនិតទាន់សម័យគេគួរតែញែកឱ្យដាច់ស្រឡះរវាងការការពារកិត្តិស័ព្ទ និងការទប់ស្កាត់ឬការផ្ដន្ទាទោសពីការធ្វើអោយខូចខាតដល់សន្តិភាព ។ ការដាក់ពន្ធនាគារលែងចាត់ទុកជាវិធីសមស្រប សំរាប់ការផ្ដន្ទាទោសលើបទបរិហាកេរ្ដិ៍ទៀតហើយ ឬក៏ពិតណាស់ថា ច្បាប់ព្រហ្មទណ្ឌលែងត្រូវយកមកប្រើចំពោះបទបរិហាកេរ្ដិ៍ហើយ ។ នៅក្នុងប្រទេសជាច្រើន សូម្បីតែសំណងតាមច្បាប់រដ្ឋប្បវេណីក៏កម្រមានអនុវត្តចំពោះឥស្សរជននយោបាយ រដ្ឋាភិបាល ឬសូម្បីតែចំពោះមន្ត្រីសាធារណៈ ក៏គួរត្រូវកំនត់ន័យអោយបានទូលាយជាងនេះ ។

៥០- នៅក្នុងប្រទេសមួយចំនួន ដែលបទបញ្ញត្តិបរិហាកេរ្ដិ៍មានចែងនៅក្នុងទ្រឹស្ដីច្បាប់ព្រហ្មទណ្ឌនោះ ក៏គេកម្រប្រើវាដែរ ។ ឧទាហរណ៍ នៅប្រទេសបារាំង ច្បាប់សារព័ត៌មានឆ្នាំ១៨៨១ នៅតែផ្ដន្ទាទោសបទល្មើសដែលប្រព្រឹត្តចំពោះប្រធានាធិបតី (មាត្រា២៦) ប៉ុន្តែតាមការជាក់ស្តែង គេឈប់សំអាងលើមាត្រានេះទៀតហើយ ចាប់តាំងពីទសវត្សឆ្នាំ១៩៦០មកម្ល៉េះ ហើយនេះមិនមែនដោយសារតែប្រជាពលរដ្ឋបារាំង ឈប់ប្រព្រឹត្តល្មើសទៅលើប្រធានាធិបតីរបស់ពួកគេនោះទេ ។ នៅក្នុងប្រទេសមួយចំនួនទៀត គេបានលប់ចោលការបរិហាកេរ្ដិ៍ពីបទល្មើសព្រហ្មទណ្ឌហើយ ។ នៅពេលរដ្ឋាភិបាលស្រីលង្កាបានរាយការណ៍ពីបំណងរបស់ខ្លួនចំពោះការសំរេចបែបនេះទៅគណៈកម្មការសិទ្ធិមនុស្ស រដ្ឋាភិបាលបាននិយាយថា "ការលុបចោលបទបញ្ញត្តិទាំងនេះ ដែលជាសំណល់ដ៏សំខាន់ពីរបបអាណានិគមនិយម ប្រទេសស្រីលង្កាគួរតែចូលរួមជាមួយការព្រមព្រៀងរួមជាអន្តរជាតិ ដែលយល់ឃើញថាបទបញ្ញត្តិទាំងនេះគឺជាការគាបសង្កត់ ហើយលែងមានភាពចាំបាច់ទៀតហើយ" (របាយការណ៍លេខ CCPR/C/LKA/2002/4, វគ្គខណ្ឌទី៣៦០) ។

៥១- បណ្តាអ្នករាយការណ៍ពិសេសអំពីការលើកស្ទួយ និងការការពារសិទ្ធិមានសេរីភាពក្នុងការសំដែងមតិយោបល់ បានផ្តល់អនុសាសន៍ជាច្រើនលើកច្រើនសាររួចមកហើយអំពីការប្រើច្បាប់ព្រហ្មទណ្ឌលើបទបរិហាកេរ្តិ៍ ។ចំណុចទាំងឡាយដែលអ្នកទាំងនោះបានលើកឡើង រួមមានដូចជា កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មិនចាត់ទុកការខូចខាតដល់រដ្ឋាភិបាល មកថាជាការរិតត្បិតស្របច្បាប់ចំពោះសេរីភាពក្នុងការនិយាយស្តីទេ, ការការពារពិសេសមិនគួរផ្តល់អោយមន្ត្រីជាន់ខ្ពស់សាធារណៈតាមរយៈច្បាប់ព្រហ្មទណ្ឌទេ, បញ្ហានៃការពិត ឬការមិនពិត គួរតែជាបញ្ហាសំរាប់អយ្យការធ្វើការកំណត់, ហើយការដាក់ពន្ធនាគារចំពោះបទបរិហាកេរ្តិ៍មិនគួរត្រូវបានអនុញ្ញាតទៀតឡើយ ។

៥២- នៅក្នុងរបាយការណ៍ដំបូងរបស់ខ្លួន ដាក់ជូនគណៈកម្មាធិការសិទ្ធិមនុស្ស រដ្ឋាភិបាលកម្ពុជា បាននិយាយថា "កន្លងមក អ្នកនិពន្ធកាសែតមួយចំនួនប្រើប្រាស់សិទ្ធិរបស់គេហួសព្រំដែន ។ ពួកគេមិនសំដែងមតិរបស់ខ្លួនធ្វើការរិះគន់រាជរដ្ឋាភិបាលឡើយ ប៉ុន្តែជេរប្រមាថសហនាយករដ្ឋមន្ត្រីដោយឥតលាក់លៀម ។ ឧទាហរណ៍ ពួកគេធ្វើអត្ថាធិប្បាយ និងគូររូបតុ្លកពិពណ៌នាថា ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសរបស់ក្រុមចោរប្លន់គ្រប់គ្រងដោយអ្នកដឹកនាំរដ្ឋាភិបាលចោរ ។ល ។ ប្រឈមមុខនឹងស្ថានភាពអាណាធិបតេយ្យ និងឥតសណ្តាប់ធ្នាប់បែបនេះ ការដែលដាក់អ្នកដឹកនាំអោយទទួលរងនូវចរន្តនៃការរិះគន់ដោយគ្មានមូលដ្ឋានស្ទើរតែជាប្រចាំ និងភាពអាម៉ាស់ ព្រមទាំងទទួលរងការជេរប្រមាថកាតទាន ធ្វើអោយការបំពេញភារកិច្ចរបស់ខ្លួនស្ទើរតែមិនអាចដំណើរការបាន ។ អាស្រ័យហេតុនេះ រដ្ឋាភិបាលក៏គ្មានជំរើសអ្វីក្រៅពីប្តឹងបញ្ហាទាំងនេះទៅតុលាការដែរ ។ "របាយការណ៍លេខ (CCPR/C/81/ Add. 12 វាក្យខ័ណ្ឌទី២៩១) ។ ប្រការនេះបាននិយាយយោងដល់ទសវត្សឆ្នាំ១៩៩០ ហើយប្រហែលជាដោយការគោរពចំពោះឋានៈនៃប្រទេសកម្ពុជា ជាប្រទេសប្រជាធិបតេយ្យនៅក្មេងខ្ចី ទើបគណៈកម្មាធិការសិទ្ធិមនុស្សមិនបានផ្តល់មតិលើរបាយការណ៍នេះ នៅពេលគណៈកម្មាធិការបានយកមកពិចារណា នាសម័យប្រជុំលើកទី៦៦ ។

៥៣- ប៉ុន្តែរដ្ឋាភិបាលទំនងជាគ្មានឆន្ទៈអនុគ្រោះទៀតទេដល់ការរិះគន់ប្រភេទណាមួយក៏ដោយ ហើយត្រៀមខ្លួនជាស្រេចដើម្បីលើកយកច្បាប់បរិហាកេរ្តិ៍ដែលមានន័យទូលាយមកសំអាង ។ ប្រាកដណាស់ថា ច្បាប់ល្អៗគួរតែត្រូវមាន ប៉ុន្តែនៅពេលដែលរដ្ឋាភិបាលមានជំរើសមួយផ្សេងទៀត រដ្ឋាភិបាលគួរតែជៀសវាងធ្វើការណែនាំដែលបង្ខំឱ្យប្រើប្រាស់ច្បាប់មិនល្អដែលមានស្រាប់ ។

៥៤- លោកតំណាងពិសេសសន្និដ្ឋានថា ការដែលរដ្ឋាភិបាលប្រើបញ្ញត្តិច្បាប់ស្តីពីការបរិហាកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និងការញុះញង់ គឺមិនស្របទៅនឹងរដ្ឋធម្មនុញ្ញកម្ពុជា និងសន្ធិសញ្ញាអន្តរជាតិនានា ស្តីពីសិទ្ធិមនុស្សទេ, ការផ្តន្ទាទោសដាក់ពន្ធនាគារមិនគួរត្រូវប្រើចំពោះបទបរិហាកេរ្តិ៍ទៀតទេ, ការប្រើបញ្ញត្តិច្បាប់ស្តីពីការបរិហាកេរ្តិ៍

គឺជាការរំលោភច្បាប់ ជាការដាក់កំហិតដល់ដំណើរវិវត្តន៍នៃលិទ្ធិប្រជាធិបតេយ្យ និងមិនអនុញ្ញាត្តអោយប្រជាជនកម្ពុជាមានឱកាសសំដែងមតិ និងស្តាប់ទស្សនៈផ្សេងៗ, និងការផ្តន្ទាទោសចំពោះការសំដែងមតិ យ៉ាងហោចណាស់ការសំដែងជាពាក្យពេចន៍ដ៏សមហេតុផលនោះ គឺជាការផ្ទុយនឹងច្បាប់កម្ពុជា ។ អាស្រ័យហេតុនេះ លោកតំណាងពិសេសស្នើយ៉ាងទទូចឱ្យរដ្ឋាភិបាលពិចារណាឱ្យបានម៉ត់ចត់ ដើម្បីព្យួរ និងលុបចោលបទបញ្ញត្តិទាំងនេះ ចេញពីច្បាប់អ៊ុនតាក់ ដែលជាសំណល់ដ៏អភ័ព្វ ពីអតីតកាលដ៏ច្របូកច្របល់របស់ប្រទេសកម្ពុជា ចំពោះការចោទប្រកាន់ទាំងអស់តាមបទបញ្ញត្តិទាំងនេះ ត្រូវតែលើកលែងចោទប្រកាន់ ហើយត្រូវធ្វើការដោះលែងជនទាំងឡាយដែលកំពុងជាប់ឃុំឱ្យមានសេរីភាពវិញ ។ ក្រមព្រហ្មទណ្ឌថ្មី ដែលកំពុងព្រាងសព្វថ្ងៃនេះផ្តល់ឱកាសល្អមួយដល់ការធ្វើវិសោធនកម្មច្បាប់នេះ ដើម្បីធ្វើឱ្យស្របជាមួយរដ្ឋធម្មនុញ្ញ និងកាតព្វកិច្ចរបស់ប្រទេសកម្ពុជាចំពោះសន្ធិសញ្ញា ។

## គ- រឿងក្តីថ្មីៗ

៥៥- សកម្មជន និងឥស្សរជនល្បីឈ្មោះមួយចំនួន ដែលបំរើការក្នុងជីវភាពសាធារណៈ ត្រូវបានចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និងការញុះញង់ នៅក្នុងត្រីមាសចុងក្រោយនៃឆ្នាំ២០០៥ ។ បណ្តឹងភាគច្រើនដែលប្តឹងដោយរដ្ឋាភិបាល ហើយត្រូវបានតុលាការចាត់ការភ្លាមៗ ជារឿងក្តីទាក់ទងនឹងការសំដែងមតិពីបញ្ហាព្រំដែន នៅក្នុងបរិបទនៃកិច្ចព្រមព្រៀងបន្ថែមស្តីពីបញ្ហាព្រំដែន ។ លោកនាយករដ្ឋមន្ត្រីហ៊ុន សែនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះជាមួយរដ្ឋាភិបាលនៃប្រទេសវៀតណាម កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៥ ហើយត្រូវបានព្រះមហាក្សត្រនរោត្តម សីហមុនី ផ្តល់សច្ចាប័នកាលពីថ្ងៃទី៣០ ខែធ្នូ ។ លោកតំណាងពិសេសយល់ពីភាពរសើបនៃបញ្ហាព្រំដែននៅប្រទេសកម្ពុជា ប៉ុន្តែលោកជឿថា បញ្ហាទាំងនេះ ជាការប្រសើបំផុតនោះគួរត្រូវលើកយកមកដោះស្រាយតាមរយៈការសន្ទនាគ្នា និងការពិភាក្សាដេញដោលជាសាធារណៈ ។ លោកមានការព្រួយបារម្ភផងដែរថារដ្ឋាភិបាលអាចឆ្លៀតប្រើប្រាស់ឱកាសនៃកិច្ចព្រមព្រៀងព្រំដែននេះ ធ្វើជាមធ្យោបាយដើម្បីបំបិទសំលេងរិះគន់ ។

៥៦- លោកម៉ម សូណង់ដូ ជាម្ចាស់ និងជានាយកស្ថានីយ៍វិទ្យុមួយដែលមានប្រជាប្រិយភាព ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី១១ ខែតុលា ពីបទបរិហារកេរ្តិ៍ ហើយបន្ទាប់មកពីបទផ្សាយព័ត៌មានមិនពិត ពាក់ព័ន្ធនឹងបទសម្ភាសន៍តាមទូរស័ព្ទមួយជាមួយប្រធានគណៈកម្មាធិការកិច្ចការព្រំដែនកម្ពុជានៅទីក្រុងប៉ារីស ដែលបានធ្វើការរិះគន់នាយករដ្ឋមន្ត្រីថា "បានលក់" កោះត្រល់ទៅឱ្យប្រទេសវៀតណាមតាមសន្ធិសញ្ញាមួយចំនួនដែលលោកនាយករដ្ឋមន្ត្រីបានចុះហត្ថលេខាជាមួយប្រទេសវៀតណាមនៅក្នុងទសវត្សឆ្នាំ១៩៨០ ។ នៅថ្ងៃទី១១ ខែតុលា លោករ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ និងប្រធានសហជីពបីរូបទៀត គឺលោកម៉ែន ណាត ប្រធានសមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា លោកជា មុនី ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា និងលោកអៀ ចាន់ណាអគ្គលេខាធិការរងនៃចលនានិស្សិតដើម្បីលិទ្ធិប្រជាធិបតេយ្យ បានចេញសេចក្តីថ្លែងការណ៍មួយធ្វើការអំពាវនាវឱ្យ

"កម្មករ និយោជិត និស្សិត ព្រះសង្ឃ មន្ត្រីរាជការ គ្រូបង្រៀន រាជវង្សានុវង្ស និងប្រជាពលរដ្ឋកម្ពុជាទាំងអស់ ចូលរួមកាន់ទុក្ខចំពោះភាពគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរចំពោះបូរណភាពទឹកដីនៃប្រទេសកម្ពុជា" ។ លោករ៉ុង ឈុន ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៥ ខែតុលា ពីបទបរិហាកេរ្តិ៍ និងពីបទញុះញង់អោយប្រព្រឹត្តបទឧក្រិដ្ឋ និងបទមជ្ឈឹមដោយពុំបានសំរេចផល ។ អ្នកដទៃទៀតត្រូវបានចោទប្រកាន់ពីបទដូចគ្នានេះដែរ ប៉ុន្តែពួកគេស្ថិតនៅក្រៅប្រទេសកម្ពុជា ។ លោកម៉ម សូណង់ដូ និងលោករ៉ុង ឈុន ត្រូវបានឃុំខ្លួននៅក្នុងមណ្ឌលកែប្រែទី១ ។ រាល់ការស្នើសុំនៅក្រៅឃុំបណ្តោះអាសន្នរបស់ពួកគេ ត្រូវបានតុលាការបដិសេធ ហើយកាលបរិច្ឆេទសំរាប់សវនាការមិនទាន់បានកំណត់នៅឡើយ ។ លោកតំណាងពិសេសបានអំពាវនាវឱ្យដោះលែងអ្នកទាំងនោះអោយបានឆាប់ ។

៩៧- ទីប្រឹក្សាពីររូបរបស់អតីតព្រះមហាក្សត្រនរោត្តមសីហនុ គឺព្រះអង្គម្ចាស់ស៊ីសុវត្ថិធម្មិកោ និងអ្នកច្បាប់ សាយ បូរី ក៏ត្រូវបានចោទប្រកាន់ផងដែរពីបទបរិហាកេរ្តិ៍ ពាក់ព័ន្ធនឹងការសំដែងមតិរបស់លោកអំពីបញ្ហាព្រំដែននេះ ។ លោកសាយ បូរី បានសំដែងទស្សនៈតាមរយៈលិខិតផ្ទាល់ខ្លួនថ្វាយអតីតព្រះមហាក្សត្រ ហើយលិខិតនោះត្រូវបានដាក់នៅក្នុងគេហទំព័ររបស់ព្រះអង្គ ដែលសាធារណជនអាចបើកមើលបាន ។ ទស្សនៈរបស់ព្រះអង្គម្ចាស់ធម្មិកោ ដែលបានចាកចេញពីប្រទេសកម្ពុជារយៈពេលដ៏ខ្លីមុនការចោទប្រកាន់ ក៏ត្រូវបានដាក់នៅក្នុងគេហទំព័រខាងលើនេះដែរ ។ លោកសាយ បូរី បានស្ថិតនៅក្រៅប្រទេសកម្ពុជា ហើយមិនអាចវិលត្រឡប់មកប្រទេសកម្ពុជាវិញ ចាប់តាំងពីពេលនោះមក ។

៩៨- នៅពេលដែលលោកកំពុងសរសេរបញ្ចប់របាយការណ៍នេះ លោកតំណាងពិសេសមានការភ្ញាក់ផ្អើល និងស្រងាកចិត្តជាខ្លាំង ដោយបានដឹងថា នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៥ មានការចាប់ខ្លួន និងឃុំខ្លួនលោក កឹម សុខា ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងលោកយ៉េង វីរៈ នាយកមជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ និងការចាប់ខ្លួនលោកប៉ា ងួនទៀង អនុប្រធានរបស់លោកកឹម សុខា នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០០៦ ។ អ្នកទាំងនេះត្រូវបានតុលាការចោទប្រកាន់ ពីបទបរិហាកេរ្តិ៍ ហើយត្រូវបានឃុំខ្លួនភ្លាម នៅមណ្ឌលកែប្រែទី១ ។

៩៩- តុលាការបានចាត់ការបណ្តឹង ដែលបានប្តឹងដោយរដ្ឋាភិបាល ពាក់ព័ន្ធនឹងបដាឃោសនាបោះឆ្នោតឆ្នាំ២០០៣ មួយរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាដែលមជ្ឈមណ្ឌលបានយកមកប្រើជាថ្មីនៅក្នុងទិវាសិទ្ធិមនុស្សដែលអង្គការក្រៅរដ្ឋាភិបាលបានប្រារព្ធធ្វើនៅពីថ្ងៃទី១០ ខែធ្នូ នៅទីក្រុងភ្នំពេញ ។ អ្នករៀបចំបានទទួលការអនុញ្ញាតពីអាជ្ញាធរក្នុងពេលដ៏ខ្លីមុនការរៀបចំទិវានេះ ។ ការចោទប្រកាន់ពីបទបរិហារកេរ្តិ៍នេះ ផ្អែកលើសារជាច្រើននៅលើបដាដែលសាធារណជនបានសរសេរក្នុងអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ដែលសារទាំងនេះបានរិះគន់រដ្ឋាភិបាល និងនាយករដ្ឋមន្ត្រី ។ បដានេះបានត្រូវទំលាក់ចុះភ្លាម បន្ទាប់ពីនគរបាលបានប្រាប់ ។ លោកតំណាងពិសេសសូមចូល

រួមសំដែងការសោកស្តាយទាំងស្រុងដូចដែលលោកស្រីឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សបានថ្លែងនៅក្នុងសេចក្តីថ្លែងការណ៏មួយដែលបានចេញផ្សាយ កាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០០៦ អំពីព្រឹត្តិការណ៏ទាំងនេះ ។

៦០- រឿងក្តីទាំងអស់នេះ បានបង្ហាញឱ្យឃើញពីភាពមិនប្រក្រតីធ្ងន់ធ្ងរជាច្រើន ។ បើតាមនីតិវិធី ការចាប់ខ្លួនទាំងនេះមិនស្របច្បាប់ទេ ។ តាមច្បាប់កម្ពុជា ដីកានាំខ្លួនអាចចេញបាន តែក្នុងករណីដែលជនជាប់ចោទ មិនព្រមមកបង្ហាញខ្លួននៅចំពោះមុខតុលាការតាមកាលបរិច្ឆេទកំណត់ ក្រោយពីបានទទួលដីកាកោះតាមពេលវេលាដ៏សមរម្យរួចហើយ ។ ក្នុងករណីនេះ គ្មានដីកាកោះណាមួយបានបញ្ជូនដល់ពួកគេទេ ។ ចៅក្រមស៊ើបអង្កេតបានចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ដោយមិនបានផ្តល់លំអិតពីមូលដ្ឋានច្បាប់នៃការសំរេចរបស់ខ្លួនអនុលោមទៅតាមមាត្រា១៤នៃច្បាប់អ៊ុនតាក់នោះទេ ។ ការចោទប្រកាន់ពីបទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ និងបទមជ្ឈឹមដោយពុំបានសំរេចផលត្រូវតែបញ្ជាក់ពីបទឧក្រិដ្ឋ ឬបទមជ្ឈឹមដែលបានប្រព្រឹត្តនោះ ប៉ុន្តែគ្មានបទល្មើសណាមួយត្រូវបានបញ្ជាក់ទេ ។

## ឃ- សង្គមស៊ីវិល និងសេរីភាពក្នុងការបង្កើតសមាគម និងការប្រជុំ

៦១- ប្រទេសកម្ពុជាមានអង្គការសកម្មជាច្រើន ដូចជាអង្គការមហាជន អង្គការក្រៅរដ្ឋាភិបាល និងអង្គការដែលមានមូលដ្ឋាននៅតាមសហគមន៏ ដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារ ការលើកស្ទួយសិទ្ធិមនុស្ស និងក្នុងការរួមចំណែកដល់ការអភិវឌ្ឍន៏ប្រទេសរបស់ខ្លួនតាមបែបប្រជាធិបតេយ្យ និងប្រកបដោយចិរភាព ។ កំឡុងពេលបំពេញទស្សនកិច្ចរបស់លោក លោកតំណាងពិសេសមានការពេញចិត្តយ៉ាងខ្លាំងចំពោះការងាររបស់ពួកគេ ។ នេះគឺជាការសំខាន់បំផុតដែលពួកគេត្រូវបានអនុញ្ញាតឱ្យបន្តរួមចំណែកក្នុងការអភិវឌ្ឍន៏ប្រទេសកម្ពុជា ។ លោកតំណាងពិសេសបានទទួលរបាយការណ៏ជាច្រើនអំពីការដាក់កំហិត និងការបំភិតបំភ័យ ដែលពួកគេប្រឈមមុខ ។ ការគំរាមកំហែងចាត់វិធានការតាមផ្លូវច្បាប់ ប្រឆាំងនឹងសកម្មជននានា ក៏កំពុងតែកើនឡើងជាមួយនឹងសកម្មជនធ្វើការនៅតាមមូលដ្ឋានដើម្បីការពារធនធានធម្មជាតិ និងជីវភាពរស់នៅតាមជនបទ ដែលងាយទទួលរងគ្រោះជាពិសេស ។ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៥ ក្រសួងមហាផ្ទៃបានចេញគោលការណ៏ណែនាំដើម្បីគាំទ្រដល់ក្រុមប្រឹក្សាឃុំសង្កាត់ហើយត្រូវបានអាជ្ញាធរខេត្តភាគច្រើនយកមកប្រើប្រាស់ទាំងបង្ខំចិត្ត ។

៦២- នៅពេលថ្មីៗនេះ រដ្ឋាភិបាលបានធ្វើអោយសេចក្តីព្រាងច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាលដែលបានពិភាក្សាតាំងពីឆ្នាំ១៩៩៥មក រស់ឡើងវិញ ហើយក្រសួងមហាផ្ទៃ បានស្នើសុំឱ្យធនាគារពិភពលោក ជួយព្រាងច្បាប់នេះ ។ បញ្ហានានាដែលមាននៅក្នុងសេចក្តីព្រាងច្បាប់មុនៗ រួមមានការបញ្ជាក់ពីការចុះបញ្ជីការ និងតម្រូវការខាងរចនាសម្ព័ន្ធសំរាប់ការដាក់កំហិតដល់សមាគម និងអង្គការក្រៅរដ្ឋាភិបាលពីប្រភពមូលនិធិ និងពីលទ្ធភាពនៃការរំលាយ

អង្គការក្រៅរដ្ឋាភិបាលឬសមាគមដោយសេចក្តីសំរេចរដ្ឋបាល ។ វានឹងមានសារៈសំខាន់ ប្រសិនបើអនុញ្ញាតឱ្យមានការចូលរួមឱ្យបានទូលំទូលាយ និងប្រកបដោយអត្ថន័យពីអង្គការក្រៅរដ្ឋាភិបាលក្នុងការព្រាងច្បាប់នេះ ជាពិសេសអង្គការសិទ្ធិមនុស្សនិងអង្គការតស៊ូមតិនានា ។ វាក៏នឹងមានសារៈរសំខាន់ផងដែរ ប្រសិនបើធ្វើការពិគ្រោះយោបល់ជាមួយការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស ដើម្បីធានាថាច្បាប់នេះស្របតាមរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្សដែលតំរូវអោយប្រទេសកម្ពុជាជាប់កាតព្វកិច្ច និងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិនិងការទទួលខុសត្រូវរបស់បុគ្គល ក្រុម និងអង្គការសង្គម ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ដែលត្រូវបានទទួលស្គាល់ជាសកល ( សេចក្តីសំរេចរបស់មហាសន្និបាតលេខ ៥៣/១៤៤) ។

៦៣- រដ្ឋាភិបាលក៏កំពុងព្រាងច្បាប់ថ្មីមួយ ស្តីពីសេរីភាពនៃការប្រជុំ និងការធ្វើបាតុកម្មអហឹង្សាដែលបានក្លាយមកជាពន្លឺដល់សាធារណជននៅក្នុងអំឡុងពេលបំពេញបេសកកម្មរបស់លោកតំណាងពិសេស ។ ជាថ្មីម្តងទៀត វានឹងមានសារៈសំខាន់ ប្រសិនបើមានការចូលរួមពិគ្រោះយោបល់ជាសាធារណៈអោយបានទូលំទូលាយដើម្បីធ្វើឱ្យច្បាប់នេះស្របទាំងស្រុងទៅនឹងរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាអន្តរជាតិ និងធ្វើការពិគ្រោះយោបល់ជាមួយអង្គការពលកម្មអន្តរជាតិ និងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស អំពីបញ្ហានេះ ។ ការធ្វើច្បាប់សំខាន់បែបនេះ ដោយប្រញាប់ប្រញាល់ពេក គ្មានហេតុផលល្អទេ ហើយត្រូវរកគ្រប់ហេតុផលទាំងអស់ដើម្បីកែតំរូវចំនុចខ្វះខាតទាំងឡាយនៅក្នុងច្បាប់នេះដែលមិនស្របនឹងរដ្ឋធម្មនុញ្ញ ។

៦៤- លោកតំណាងពិសេស បានទទួលរបាយការណ៍ជាច្រើន អំពីការបន្តមិនគោរពសិទ្ធិនៃការប្រជុំដោយសន្តិវិធី ។ ការអនុវត្តន៍សិទ្ធិទាំងនេះ នៅតែត្រូវបានបដិសេធជាប្រចាំ ដោយមូលហេតុតាមទំនើងចិត្ត ។ ប្រសិនបើបាតុកម្ម ឬការប្រជុំផ្សេងៗ បានប្រារព្វធ្វើដោយគ្មានការអនុញ្ញាត កំលាំងហួសប្រមាណត្រូវបានប្រើប្រាស់នៅពេលខ្លះទៅលើអ្នកតវ៉ាទោះជាការតវ៉ានោះដោយសន្តិវិធីក្តី  អ្នកដឹកនាំបាតុកម្មត្រូវបានចាប់ឃុំខ្លួន និងបង្ខំឱ្យផ្តិតមេដៃលើកសំណុំឯកសារ សន្យាថានឹងឈប់ធ្វើឱ្យខូចសណ្តាប់ធ្នាប់សាធារណៈទៀតហើយ ឬត្រូវបានចោទប្រកាន់ ហើយបញ្ជូនទៅតុលាការ ។ លោកមានការព្រួយបារម្ភផងដែរ កាលដឹងថាបច្ចុប្បន្ន នគរបាលកាន់ និងប្រើប្រាស់ដំបងឆក់ជាប្រចាំនោះ ។

## VII- សេចក្តីសន្និដ្ឋាន និងអនុសាសន៍

៦៥.លោកតំណាងពិសេសនៃលោកអគ្គលេខាធិការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានសិក្សាយ៉ាងយកចិត្តទុកដាក់ នូវកំរងអនុសាសន៍ជាច្រើន ដែលបានបង្ហាញដោយលោកតំណាងពិសេសមុនៗ ហើយលោកកត់សំគាល់ថា អនុសាសន៍ជាច្រើននៅតែមានសុពលភាពនៅឡើយ ព្រោះថាបញ្ហាទាំងឡាយដែលបានស្នើសុំឱ្យដោះស្រាយ នៅពុំទាន់បានដោះស្រាយនៅឡើយ។ លោកសង្ឃឹមថានឹងធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីរិះរកមធ្យោបាយអនុវត្តអនុសាសន៍ទាំងនោះ ដោយមិនត្រូវអូសបន្លាយពេលវេលាតទៅទៀតឡើយ។ ម្យ៉ាងវិញទៀត លោកសូមធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោមនេះ ដោយផ្អែកលើការសង្កេត និងការរកឃើញដំបូងរបស់លោក។

៦៦. លោកតំណាងពិសេសមានការព្រួយបារម្ភជាខ្លាំង អំពីដំណើរការធ្លាក់ចុះនៃបរិយាកាសសំរាប់ការអនុវត្តន៍ និងការចូលរួមក្នុងដំណើរការប្រជាធិបតេយ្យ ដែលវារិតតែលំបាកថែមទៀតចំពោះអ្នកនយោបាយប្រឆាំង សហជីពកម្មករ អ្នកសារព័ត៌មាន សង្គមស៊ីវិល និងអង្គការសិទ្ធិមនុស្ស ក្នុងការសម្តែងមតិ ឬការអនុវត្តន៍សកម្មភាពរបស់ខ្លួនដោយសេរី។ ចំណាប់អារម្មណ៍ជាទូទៅ របស់លោកតំណាងពិសេសគឺថា សេរីភាពជាមូលដ្ឋាន និងលិទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជាកំពុងប្រឈមនឹងគ្រោះថ្នាក់។ ការបន្ត និងការកើនឡើងនៃការចោទប្រកាន់ពីការបរិហារកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និងការញុះញង់ទៅលើអ្នកនយោបាយប្រឆាំង និងការខ្វែងគំនិត យោបល់គ្នា គឺជាបញ្ហាដែលគួរឱ្យព្រួយបារម្ភបំផុត។ លោកតំណាងពិសេសមានទស្សនៈរឹងមាំថា បញ្ហាពាក់ព័ន្ធផលប្រយោជន៍សាធារណៈ បើទោះជាបញ្ហានោះរសើបខ្លាំង ឬអាចមានវិវាទក៏ដោយ ក៏គួរតែចាត់ការ ឬដោះស្រាយតាមរយៈការពិភាក្សា និងការជជែកដេញដោលគ្នា ហើយមិនចាំបាច់ដោះស្រាយតាមរយៈតុលាការឡើយ។ រដ្ឋាភិបាល និងស្ថាប័នរដ្ឋដទៃទៀត ត្រូវចាត់វិធានការជាបន្ទាន់ ដើម្បីស្តារបរិយាកាសនេះឡើងវិញ ដែលជំរុញឱ្យមានការជជែកដេញដោលជាសាធារណៈ ការគ្រប់គ្រងប្រកបដោយតម្លាភាព និងមានការទទួលខុសត្រូវ ព្រមទាំងការអនុវត្តន៍សិទ្ធិតាមបែបប្រជាធិបតេយ្យ។ សេរីភាពក្នុងការសម្តែងមតិ ការបង្កើតសមាគម និងការប្រជុំដោយសន្តិវិធី ត្រូវតែគោរព និងលើកស្ទួយ។

៦៧. នៅពេលលោកតំណាងពិសេសបានសំដែងការព្រួយបារម្ភរបស់លោកជូនរដ្ឋមន្ត្រីនានា អំពីស្ថានភាពសិទ្ធិមនុស្ស និងដំណើរធ្លាក់ចុះនៃបរិយាកាសសំរាប់ការអនុវត្តន៍ និងការចូលរួមអនុវត្តន៍លិទ្ធិប្រជាធិបតេយ្យ រដ្ឋមន្ត្រីទាំងនោះបានប្រាប់លោកថា រដ្ឋាភិបាលគ្រាន់តែអនុវត្តការទទួលខុសត្រូវរបស់ខ្លួន ក្នុង

ការប្រតិបត្តិច្បាប់តែប៉ុណ្ណោះ ហើយថាច្បាប់ភាគច្រើនដែលកំពុងមានបញ្ហាត្រូវបានអនុម័តដោយអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំកម្ពុជា។ លោកតំណាងពិសេស មិនឯកភាពលើទស្សនៈនេះទេ ព្រោះថាច្បាប់នេះត្រូវបានព្រាងឡើងដោយអ៊ុនតាក់ ហើយត្រូវបានអនុមត័ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដើម្បីប្រើប្រាស់តែក្នុងសម័យអន្តរកាល សំរាប់ដោះស្រាយតែស្ថានភាពមួយពិសេសប៉ុណ្ណោះ ហើយច្បាប់នេះត្រូវបានបង្កើតឡើង នៅក្នុងពេលដែលប្រទេសកម្ពុជាមិនទាន់មានបទបញ្ញត្តិគតិយុត្តិស្តីពីសិទ្ធិមនុស្ស។ ចាប់ពីពេលនោះមក រដ្ឋធម្មនុញ្ញកម្ពុជាដោយមានកំរងសិទ្ធិសំខាន់ៗ និងសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើន បានត្រូវអនុម័ត។ ប្រការទាំងនេះធ្វើឱ្យទិដ្ឋភាពនៃច្បាប់អ៊ុនតាក់ អធម្មនុញ្ញភាព។ រដ្ឋាភិបាលត្រូវទទួលខុសត្រូវ ដើម្បីធានាថាបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងគោលការណ៍សិទ្ធិមនុស្សត្រូវតែលប់ចោល។

៦៨. បើទោះជាច្បាប់មួយបញ្ញត្តិពីបទល្មើសព្រហ្មទណ្ឌក្តី រដ្ឋាភិបាលមិនគំរូវអោយសំអាងលើបញ្ញត្តិនេះទេ ព្រោះថាច្បាប់នេះហួសសម័យ ដោយគំនិត និងកាលៈទេសៈមានការប្រែប្រួល ទាក់ទងទៅនឹងអ្វីដែលគេចាត់ទុកថាជាទង្វើត្រឹមត្រូវ។ ដូចបញ្ជាក់ក្នុងរបាយការណ៍នេះស្រាប់ ប្រទេសភាគច្រើនដែលពីមុនមកបានចាត់ទុក ការបរិហាកេរ្តិ៍ឬការជេរប្រមាថ ជាបទល្មើសព្រហ្មទណ្ឌ បានលប់ឬឈប់សំអាងលើច្បាប់នោះទៀតហើយ។ រដ្ឋាភិបាលត្រូវអនុវត្តឱ្យបានត្រឹមត្រូវនិងសមហេតុផលក្នុងវិធីដែលខ្លួនប្រើប្រាស់ច្បាប់។ ក្នុងបរិបទនេះ លោកតំណាងពិសេសយល់ឃើញថា ច្បាប់នេះមិនទាន់ត្រូវបានអនុវត្តស្របតាមបទដ្ឋាននៃប្រព័ន្ធច្បាប់សេរីនោះទេ។ ការដោះលែងអោយនៅក្រៅឃុំបណ្តោះអាសន្ន បានត្រូវបដិសេធជាប្រចាំ ចំពោះជនទាំងឡាយដែលរដ្ឋាភិបាលបានធ្វើការចោទប្រកាន់។ ក្នុងករណីភាគច្រើន ភស្តុតាងដែលអយ្យការសំអាងសំរាប់ធ្វើការចោទប្រកាន់ មានផ្សាយជាសាធារណៈរួចទៅហើយ ដូចជាក្នុងករណីបរិហាកេរ្តិ៍ទាំងនេះ ហើយការបង្ហាញភស្តុតាងដែលបានពីការស៊ើបអង្កេតបន្ថែមដ៏ចាំបាច់នោះ មិនអាចយកជាការបានទេ និងក្នុងករណីណាក៏ដោយ គ្មានហេតុផលសុពលណាមួយសំអាងសំរាប់ការឃុំខ្លួនបែបនេះទេ។ សរុបសេចក្តីមក ច្បាប់នេះត្រូវបានប្រើប្រាស់ដោយការជ្រើសរើស និងដោយគ្មានសមភាព។ លោកតំណាងពិសេសស្នើយ៉ាងទទូចដល់ ការផ្តល់អភ័យឯកសិទ្ធិសភាជូនសមាជិកមួយចំនួននៃគណៈបក្សប្រឆាំងសមរង្ស៊ី, ការលើកលែងរាល់ការចោទប្រកាន់ពីបទបរិហាកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិតនិងពីបទញុះញង់, ការផ្តល់ការធានាមិនអោយមានការចាប់ខ្លួនណាមួយចំពោះជនទាំងឡាយដែលនិរទេសខ្លួនទៅនៅឯបរទេសដោយសារតែបទចោទប្រកាន់ទាំងនេះ នៅពេលគេវិលត្រឡប់មកមាតុភូមិវិញ និងចំពោះជនទាំងឡាយដែលត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសពីបទបរិហាកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត និងការញុះញង់ ត្រូវដោះលែងឱ្យបានឆាប់។

៦៩. រដ្ឋធម្មនុញ្ញកម្ពុជា ដែលត្រូវបានអនុម័តដោយប្រជាពលរដ្ឋកម្ពុជា តាមរយៈតំណាងរបស់ខ្លួននៅក្នុងសភាធម្មនុញ្ញកាលពីឆ្នាំ១៩៩៣ នៅមិនទាន់ត្រូវបានអនុវត្តអោយបានពេញលេញនៅឡើយទេ ហើយការធានាការពាររដ្ឋធម្មនុញ្ញក៏ត្រូវទទួលរងការគំរាមកំហែងដែរ។ បញ្ហាជាអាទិភាពនោះគឺ រដ្ឋាភិបាលដោយធ្វើការជាមួយសង្គមស៊ីវិល គួរពង្រឹងសមត្ថភាព និងបូរណៈភាពរបស់ក្រុមប្រឹក្សាធម្មនុញ្ញនិងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រោះថា ស្ថាប័នកំពូលទាំងពីរនេះ មានតួនាទីស្នូលក្នុងការលើកកំពស់ និងការគោរពរដ្ឋធម្មនុញ្ញ។

៧០. ដូចដែលរបាយការណ៍នេះធ្វើការកត់សំគាល់ ការរីកចំរើនមានតិចតួចណាស់ ក្នុងការអនុម័តច្បាប់សំខាន់ៗមួយចំនួន បើទោះជាមានជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសពីក្រៅយ៉ាងច្រើនសន្ធឹកសន្ធាប់សំរាប់អនុវត្តកិច្ចការនេះក៏ដោយ។ នៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់សំរាប់ប្រទេសកម្ពុជា កាលពីខែធ្នូ ឆ្នាំ២០០៤ រដ្ឋាភិបាលបានឯកភាពថា គណៈរដ្ឋមន្ត្រីនឹងសំរេចលើសេចក្តីព្រាងច្បាប់សំខាន់ៗចំនួន៨ ហើយបញ្ជូនច្បាប់ទាំងនោះទៅរដ្ឋសភា នៅមុនបំណាច់ឆ្នាំ២០០៥។ ការងារនេះមិនបានសំរេចតាមការគ្រោងទុកនោះទេ។ រដ្ឋាភិបាលចាំបាច់ត្រូវតែបញ្ចប់កិច្ចដំណើរការព្រាងច្បាប់ទាំងនេះ ហើយបញ្ជូនច្បាប់ទាំងនេះទៅរដ្ឋសភា ដោយមិនត្រូវអូសបន្លាយពេលវេលាដោយមិនសមរម្យទៀតទេ។ ច្បាប់ទាំងនេះគួរតែត្រូវបានរៀបចំឡើងតាមរយៈដំណើរការចូលរួមដែលគួរជាទីពេញចិត្តមួយ ហើយសេចក្តីព្រាងច្បាប់ទាំងនេះត្រូវតែស្របនឹងរដ្ឋធម្មនុញ្ញកម្ពុជា និងសន្ធិសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស។

៧១. លោកតំណាងពិសេសក៏មានការព្រួយបារម្ភផងដែរ អំពីឯករាជ្យភាព និងបូរណៈភាពនៃតុលាការកម្ពុជា។ រដ្ឋាភិបាលគួរផ្តល់អាទិភាពខ្ពស់ដល់ការអនុម័តច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ក៏ដូចជា ការពង្រឹងឯករាជ្យភាពនៃកិច្ចដំណើរការច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការកែលំអបច្ចេកទេសក្នុងកិច្ចដំណើរការទាំងនេះ។ លោកតំណាងពិសេសកត់សំគាល់ទៀតថា មិនមានប្រព័ន្ធផ្លូវការណាមួយនៃជំនួយផ្នែកច្បាប់សំរាប់ការពារជនក្រីក្រ ឬមធ្យោបាយផ្សេងទៀត ដើម្បីជួយសំរួលដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់ប្រព័ន្ធតុលាការ និងវិជ្ជាជីវៈច្បាប់បាន។ ជាលទ្ធផល ការទទួលខុសត្រូវទាំងស្រុងក្នុងការផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ និងប្រជាពលរដ្ឋនៅតាមជនបទ បានធ្លាក់មកលើបន្ទុករបស់អង្គការសង្គមស៊ីវិលនានា ដែលខ្វះខាតធនធានហិរញ្ញវត្ថុ និងវិជ្ជាជីវៈទៅវិញ។

៧២. ដូចរបាយការណ៍នេះនិងរបាយការណ៍មុនៗបានបង្ហាញមកហើយ  មានការអនុវត្តន៍កាន់តែរីករាលដាលទៅៗនៃនិទណ្ឌភាពរបស់បុគ្គលទាំងឡាយដែលមានឋានៈខ្ពង់ខ្ពស់ខាងសេដ្ឋកិច្ច ឬនយោបាយ រឺឯអ្នកផ្សេងទៀតដែលគ្មានការគិតរាមកំហែងដល់ច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ  ហើយអនុវត្តដោយស្មោះត្រង់ បែរជាថាធ្វើអោយរដ្ឋាភិបាលក្តៅក្រហាយ ហើយត្រូវបានចោទប្រកាន់ និងផ្តន្ទាទោសទៅវិញ។ លោកតំណាងពិសេសពិចារណាថា មានលំនាំមួយក្នុងការប្រតិបត្តិច្បាប់ តាមរយៈព្រះរាជអាជ្ញា និងចៅក្រមដែលមិនគោរពនីតិវិធីច្បាប់ និងដំណើរការនីតិវិធីដ៏ត្រឹមត្រូវ ដែលអាចនិយាយបានថា ច្បាប់ត្រូវបានបំពានដោយសារគោលបំណងនយោបាយ។ គេចាំបាច់ត្រូវមានការជជែកពិភាក្សាគ្នាឱ្យបានទូលំទូលាយ និងក្នុងន័យស្ថាបនានៅក្នុងប្រទេសកម្ពុជា អំពីចរិតនិងផលប៉ះពាល់នៃនិទណ្ឌភាព និងវិធានការនានាដែលត្រូវធ្វើ ដើម្បីជំនះបញ្ហានេះ។  អនុសាសន៍ដែលអតីតតំណាងពិសេសនានា និងបណ្តាអង្គការសន្ធិសញ្ញាសិទ្ធិមនុស្ស ដែលបានដាក់ជូនកន្លងមក ដើម្បីបញ្ចប់បញ្ហានិទណ្ឌភាព ត្រូវតែយកមកអនុវត្ត។ លោកតំណាងពិសេសរង់ចាំ ធ្វើការជាមួយរដ្ឋាភិបាល និងសហគមន៍អន្តរជាតិ ដើម្បីបញ្ចប់បញ្ហានេះ ។

៧៣. សិទ្ធិខាងដីធ្លី និងផ្ទះសម្បែង កំពុងចោទជាបញ្ហាធំ។  របាយការណ៍របស់អតីតតំណាងពិសេសដាក់ជូនគណៈកម្មការសិទ្ធិមនុស្ស នាសម័យប្រជុំលើកទី៦០ បានបញ្ជាក់ពីបញ្ហាសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធនឹងគោលនយោបាយដីធ្លី (E/CN.4/2004/105, កថាខ័ណ្ឌទី៤១-៤៧)។ មានជំលោះជាច្រើនពាក់ព័ន្ធនឹងកម្មសិទ្ធិដីធ្លីដែលភាគច្រើនត្រូវបានដោះស្រាយដោយភាពលំអៀង។ សហគមន៍ជាពិសេសសហគមន៍ជនជាតិដើមភាគតិច ត្រូវបានធ្វើការផ្លាស់ប្តូរទីកន្លែង ឬបណ្តេញចេញពីដីកេរ្តិ៍ដូនតារបស់ខ្លួន ដោយគ្មានការការពារណាមួយតាមផ្លូវច្បាប់ដល់ពួកគេឡើយ។ ព្រៃឈើកំពុងតែត្រូវបានកាប់បំផ្លាញ ដល់កំរិតមួយដែលត្រូវតែប្រកាសអាសន្ន។ រាជរដ្ឋាភិបាលនៅមិនទាន់បានបង្ហាញព័ត៌មានជាសាធារណអំពីដី និងធនធានធម្មជាតិផ្សេងៗ ដែលខ្លួនបានផ្តល់សម្បទានឱ្យក្រុមហ៊ុនឯកជន និងយោធាក្រោមផ្លាកអភិវឌ្ឍន៍នោះឡើយ។របាយការណ៍ដាក់ជូនគណៈកម្មការរបស់អ្នករាយការណ៍ពិសេសខាងសិទ្ធិមានលំនៅដ្ឋានសមរម្យដែលជាផ្នែកមួយនៃសិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យ និងសិទ្ធិគ្មានការរើសអើង នៅក្នុងបរិបទនេះផ្តល់ព័ត៌មានមួយចំនួនស្តីពីការបណ្តេញចេញដោយបង្ខំ ការផ្លាស់ទីកន្លែងដោយបង្ខំ និង"ការប្តូរ" ទីតាំងដីដែលនាំឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រជាពលរដ្ឋក្រីក្រ (E/CN.4/2006/41/Add.3)។ លោកតំណាងពិសេសលើកទឹកចិត្តរដ្ឋាភិបាលអោយធ្វើការពិចារណាយ៉ាងយកចិត្តទុកដាក់ ចំពោះរបាយការណ៍នេះនិងអនុ សាសន៍នៃរបាយការណ៍នេះ។ លោកក៏ស្នើយ៉ាងទទូចផងដែរដល់រដ្ឋាភិបាលអោយធានាការអនុវត្តន៍ច្បាប់ភូមិបាលឱ្យបានឆាប់រហ័ស ព្រមទាំងផ្តល់នូវនីតិវិធីត្រឹមត្រូវ និងយុត្តិធម៌ ដើម្បីដោះស្រាយជំលោះដីធ្លី អោយស្របតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

៧៤. លោកតំណាងពិសេសសូមស្វាគមន៍ ចំពោះការចុះហត្ថលេខារបស់ប្រទេសកម្ពុជា លើពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅឆ្នាំ២០០៤ និងពិធីសារបន្ថែមនៃអនុសញ្ញាស្តីពីការលប់បំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនារីភេទ នៅឆ្នាំ២០០១។ លោកសង្ឃឹមថាពិធីសារបន្ថែមទាំងនេះ នឹងត្រូវផ្តល់សច្ចាប័ន ក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ។ លោកតំណាងពិសេសជំរុញដល់រដ្ឋាភិបាល អោយបន្តយ៉ាងសកម្មថែមទៀត ចំពោះការដាក់ជូនរបាយការណ៍លើកដំបូងរបស់ខ្លួន តាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងរបាយការណ៍តាមកាលកំណត់របស់ខ្លួន ជូនយន្តការឃ្លាំមើលសន្ធិញ្ញាអន្តរជាតិផ្សេងៗទៀត។ លោកតំណាងពិសេសសូមស្វាគមន៍ចំពោះការបញ្ចប់របាយការណ៍របស់កម្ពុជា តាមអនុសញ្ញាអន្តរជាតិ ស្តីពីការលប់បំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនារីភេទ ដែលនឹងត្រូវលើកយកមកពិចារណាក្នុងខែមករា ឆ្នាំ២០០៦នេះ។

៧៥. សហគមន៍អន្តរជាតិក៏មានតួនាទីសំខាន់ផងដែរ ក្នុងការជួយឧបត្ថម្ភគាំទ្រប្រទេសកម្ពុជាក្នុងការខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីពង្រឹងសិទ្ធិមនុស្ស និងស្ថាប័ននានាដែលមានការទទួលខុសត្រូវ និងប្រជាធិបតេយ្យ អោយបំពេញតួនាទីរបស់ខ្លួនតាមនីតិរដ្ឋ។ អនុលោមតាមការប្តេជ្ញាចិត្តរបស់ខ្លួន តាមកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមសំរាប់ជំលោះកម្ពុជា សហគមន៍អន្តរជាតិតាមរយៈអង្គការសហប្រជាជាតិ និងតាមមធ្យោបាយជាពហុភាគីក្តី និងជាទ្វេភាគីក្តី ត្រូវតែជួយរដ្ឋាភិបាលក្នុងការរៀបចំបង្កើត និងអនុវត្តគោលនយោបាយ និងកម្មវិធីនានា ដែលនឹងផ្តល់អត្ថប្រយោជន៍ ដល់ប្រទេសកម្ពុជាទាំងមូល ហើយអនុញ្ញាតឱ្យប្រជាពលរដ្ឋកម្ពុជាអនុវត្តសិទ្ធិពលរដ្ឋ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិនយោបាយរបស់ពួកគេ ដែលជាសនិទានភាពដំបូង សំរាប់ការចូលរួមរបស់ពួកគេក្នុងការកសាងប្រទេសកម្ពុជា ក្នុងកំឡុងដើមទសវត្សឆ្នាំ១៩៩០ មក។